លី ធាមតេង

# សិក្សាសង្ខេប អំពី

# អារ្យធម៌ខ្មែរ

CA26

បណ្ណាគារ សេង-ងួន-ហួត លេខ ១៨ វិថីព្រះបាទចន្ទរាជា ភ្នំពេញ

# បុព្វកថា

តាមពិត អត្ថបទនេះ កើតឡើងដោយការរៀបចំ សម្រាប់យកទៅធ្វើជាឧបករណ៍ ពន្យល់ចំពោះអ្នកត្រូវការសិក្សា « អារ្យធម៌ខ្មែរ » តាមកម្មវិធីថ្នាក់ទី ១ នៃមធ្យមភូមិ ។ លុះដល់កម្រិតនេះ ប្រមូលបានកាន់តែច្រើនឡើង ៗ ខ្ញុំក៏យល់ថា គួរតែចងទុក ជាឯកសារផ្ទាល់ខ្លួន សម្រាប់នៅពេលដែលត្រូវការស្រាវជ្រាវតទៅទៀត ។ ប៉ុន្តែ ដោយបានស្នើនូវស្នាដៃសាកល្បង (Essai) នេះ ចំពោះមិត្តភក្តិ ជាអ្នកស្រាវជ្រាវផងគ្នា និងសូមយោបល់អ្នកអាន អ្នកសិក្សាទៅផងនោះ, ខ្ញុំក៏ដាច់ចិត្ត យកស្នាដៃសាកល្បងនេះ ទៅចុះផ្សាយក្នុង ទស្សនាវដ្ដីអក្សរសាស្ត្រ ម្ដងបន្តិច ៗ ចាប់តាំងពីលេខ ២៦ ខែ មិថុនា គ.ស ១៩៦៧ ជាបន្ត ៗ ទៅលុះត្រាចប់ ។ បន្ទាប់មក ខ្ញុំក៏បានទទួលសេចក្ដីណែនាំ

បន្ថែមខ្លះ អំពីសំណាក់មិត្តភក្តិ ជាគូដៃ ក្នុងការស្រាវ-ជ្រាវ និងអំពីសំណាក់អ្នកអានខ្លះ ដែលមានចិត្តស្រឡាញ់អារ្យធម៌ខ្មែរ ។ សេចក្តីណែនាំទាំងនេះ រឹងរឹតតែធ្វើឲ្យខ្ញុំបានពេញបំណងនេះថែមឡើងទៀត ។ ដូច្នេះ ខ្ញុំសូមលំឱនកាយ គោរព អរគុណចំពោះមិត្តភក្តិ និងអស់លោក-អ្នកទាំងនេះផង ។

ក្រោយដែលប្រមូល បញ្ចូលបន្ថែមសាជាថ្មីម្តងទៀតរួចហើយ ខ្ញុំក៏យកទុកមួយអន្លើទៀត ព្រោះយល់ថា ស្នាដៃសិក្សាស្រាវជ្រាវអំពីក្បួនច្បាប់ប្រវត្តិពន្យារ-តារយ៉ាងនេះ មិនសមធ្វើដោយងាយៗទេ គួរតែទុកការងារដ៏ធំបែបនេះ ជូនគណៈកម្មការណាមួយ ឬអស់លោកអ្នកចេះដឹងជ្រៅជ្រះណាម្នាក់ លោកសរសេរឡើង ទើបសម ។ ប៉ុន្តែមានគំនិតតូចមួយចេះតែដាស់ស្មារតីខ្ញុំថា៖

ធម្មតាការស្រាវជ្រាវបើរកឃើញប៉ុនណា មានការយល់ដូចម្ដេច ; ត្រូវតែបញ្ចេញទៅសិន ដើម្បីជួយជាប្រទីបត្រាលបំភ្លឺឬជាគម្រោយសម្រាប់ផ្ដល់ចំពោះអ្នកស្រាវជ្រាវតៗ ទៅទៀត ។ ដូច្នេះ អ្នកស្រាវជ្រាវត្រូវតែមានសេរីភាព ក្នុងការបញ្ចេញយោបល់ខ្លួនជាបណ្ដើរ ៗ ទៅ ក្នុងដំណើរការងារ ហើយការងារនេះ មិនចេះចប់ឡើយ បានន័យថា អ្នកស្រាវជ្រាវ កាលបើរកឃើញដូចម្ដេច ត្រូវថាយ៉ាងនោះ លុះក្រោយទៅមានហេតុផលធំជាងមុនទៅទៀត ក៏អាច[illegible]យោបល់នោះទៅតាមការឃើញការយល់ថ្មី ទៅទៀតដែរ ។

ស្នាដៃនេះ ពុំមែនជាក្បួនតម្រា ឬជាគោលច្បាប់សម្រាប់ឲ្យអនុវត្តដោយខានមិនបានទេ តាមពិតគឺគ្រាន់តែជាជំនួយស្មារតី ឬជាយោបល់អ្នករិះរ

ម្នាក់ សម្រាប់បំភ្លឺផ្លូវចំពោះអ្នកសិក្សាជាបឋមអំពីអារ្យធម៌ជាតិ តែប៉ុណ្ណោះ ។ ដូច្នេះ បំណងក្នុងសៀវភៅនេះគឺ ÷

១– ចង់ជួយដោះទាល់អ្នកសិក្សាដោយខ្លួនឯង ហើយដែលមានប្រាជ្ញាចូលទៅប្រឡងផ្សេង ៗ ដែលទាក់ទងដល់ចំណេះវិជ្ជាខាងវប្បធម៌-អារ្យធម៌ខ្មែរ ។

២– ចង់ជួយបញ្ជាក់ ចំពោះមតិអ្នកយល់ប្រឡំថា “អារ្យធម៌”គឺជាអ្វីដែលកើតថ្មី ៗ អ្វីប្លែក ៗពីទំនៀមជាតិ, ឲ្យងាកបែរមកយល់ឲ្យច្បាស់ តាមការពិតទៅវិញ ។

៣– ចង់បង្ហាញឲ្យជនទូទៅឃើញថា អារ្យធម៌ខ្មែរ ពុំមែនចម្លង ពុំមែនទើបតែកើតតាមពួកបស្ចិមទិសទេ គឺមានផ្ទាល់ខ្លួនតាំងពីកើតជាសញ្ជាតិមួយមកម៉្លេះ ។

ទីបំផុត ខ្ញុំសូមឧទ្ទិសនូវសៀវភៅនេះ ផ្សាយ

ជូនដល់អ្នកសិក្សាទូទៅក្នុងកម្ពុជរដ្ឋ ។

ភ្នំពេញ ខែកញ្ញា ១៩៦៥

លី-ធាមតេង

## បញ្ជាក់ :

ក្នុងការបោះពុម្ពលើកទី ២ នេះ ខ្ញុំបានកែសម្រួល និងបានបន្ថែមសេចក្ដីជាច្រើន ឲ្យបានក្បោះក្បាយជាងមុនដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាទូទៅ ។

២៨-២-៦៩

លី.ធ.ត

# សិក្សាសង្ខេប

## អំពី

# អារ្យធម៌ខ្មែរ

## សេចក្ដីផ្ដើម

អ្នកផងនៅសម័យបច្ចុប្បន្ន ច្រើនតែចាប់អារម្មណ៍ថា « អារ្យធម៌ » គឺជាចំណេះវិជ្ជាថ្មីៗ ឬការតុបតែងប្លែកៗជំនាន់ថ្មី ដែលត្រូវន័យនឹងពាក្យអ្នកសព្វថ្ងៃហៅថា « ស៊ីវីល័យ » ។ តែតាមពិត អារ្យធម៌ គឺជាកម្រងចំណេះវិជ្ជាដែលមនុស្សរកឃើញ ហើយបង្កបង្កើតឡើងតាំងពី

អន្លែងហើយ ដូចអារ្យធម៌ខ្មែរ ដែលកកើតឡើងតាំងពី កទឹកកដីខ្មែរម្ល៉េះ គ្រាន់តែដំបូងនោះ មិនសរសោភកត់ទុក មានត្រឹមតែទម្លាប់ធ្វើតៗគ្នាមកប៉ុណ្ណោះ ។

បើរកឃើញនូវកំណើត និងរូបភាពអារ្យធម៌ខ្មែរ យើងប្រតិស្ឋានឡើងជាក់ប្រាកដលើដីយើង តាំងពីក ទឹកដីដូច្នោះហើយ, យើងគោងតែតាមដានសង្កេតមើល តើតាំងពីមានរូបភាពមករហូតសព្វថ្ងៃនេះ អស់រយៈវេលា ជាងពីរពាន់ឆ្នាំមកហើយនោះ មានការវិវត្តន៍យ៉ាងណា ខ្លះ ? ។ យើងដឹងមកហើយថា ពិតមែនតែមានឥទ្ធិពលនៃ អារ្យធម៌នានាជាតិ ជាពិសេសគឺជាតិណាដែលទាក់ទងនឹង ខ្មែរយើងពីមុនៗមែន ប៉ុន្តែឥទ្ធិពលទាំងនោះ រកតែបន្ថែម ឲ្យបានជាមធ្យោបាយជួយរុញច្រាន ឲ្យអារ្យធម៌ខ្មែរមាន កម្លាំង និងមានរូបរាង បែកសាច់ឈាម ពេញលេញ

បរិបូណ៌ឡើងទៅវិញ ៗ ដើម្បីបានស្គាល់ដំណើរដើម ឬប្រវត្តិហូរហែពីមុនមក យើងអាចអធិប្បាយចែករំលែកនូវប្រវត្តិអារ្យធម៌យើង តាមបែបប្រវត្តិសាស្ត្រជាបួនសម័យកាលធំៗគឺ ៖

## ១–អារ្យធម៌សម័យមុនអក្សរ

ដែលហៅថា « សម័យមុនអក្សរ » គឺសំដៅយកពេលវេលាដែលប្រវត្តិសាស្ត្រយើងប្រាប់ថា កាលនោះ មានមនុស្សមករស់នៅលើទឹកដីរបស់យើង ហើយអ្នកទាំងនោះ ចាប់ផ្តើមកសាងនូវរបៀបរបបរស់នៅរបស់ខ្លួនបន្តិច ៗ ម្តង លុះត្រាតែទៅជាមានការរៀបរយសម្រាប់សញ្ជាតិមួយឡើង ៗ ត្រង់នេះហើយ ដែលយើងសន្មតបានថា របបរស់នៅសម្រាប់ជាតិយើងដែលអ្នកប្រវត្តិសាស្ត្រឲ្យឈ្មោះថា « អារ្យធម៌ » នោះ ពិតជាក

កើតដំបូងនៅក្នុងស្រុកខ្មែរយើងនេះជាប្រាកដ ។

ដូច្នេះ ពេលវេលាដែលកំណត់រយៈកាលនេះចាប់ផ្ដើមឡើងតាំងពីកាលមុនគ្រិស្តសករាជ ទៅទៀត ហើយមានរយៈពេលតរហូតមក ដល់សម័យដែលជនជាតិយើងរស់នៅតាមអាណាចក្រតូចតាចៗដោយឡែកពីគ្នា មានអាណាចក្រភ្នំ ( ហ្វូណន ) អាណាចក្រកម្ពុជ (ចិនហៅ ចេនឡា ) ជាដើម, លុះគ្រាដល់ពេលរួបរួមគ្នាជាអាណាចក្រធំមួយ ទើបក្រុងទៅប្រតិស្ឋាននៅឯខាងជើងបឹងទន្លេសាប ដែលហៅថា " អង្គរ ,, ។

សម័យកាលដ៏ធំនេះ តាំងពីចាប់ផ្ដើមមក, យើងសង្កេតឃើញថា ជាពេលចំរើនឥតឈប់ឈរ ធៀបឧបមាបីដូចជាឈើដែលទើបតែដុះ ហើយលូតលាស់ជាលំដាប់ រហូតទាល់បានជាទ្រង់ទ្រាយរុក្ខជាតិធ្លូនល្មម ។

ជាប់ពីមុនគ្រិស្តសករាជ មកទាល់គ្រានៃសតវត្សទី១, អារ្យធម៌ខ្មែរ ពុំទាន់លេចឈ្មោះពេញទីនៅឡើយមែន ប៉ុន្តែបើមើលពីកេរ្តិ៍ដំណែលជាសក្ខីភាព ក៏គង់ឃើញនៅសេសសល់ច្រើនណាស់ ដូចជាប្រាសាទតូចតាចនៅគង់ក្នុងភាគអង្គរបុរី ប្រាសាទសង់ពីឥដ្ឋនៅសម្បូរព្រៃគុកខេត្តកំពង់ធំសព្វថ្ងៃ, ល្បែងរបាំប្រពៃណីច្រើនបែបច្រើនយ៉ាង និងភាសានិយាយស្តីសម្រាប់ប្រស្រ័យគ្នារហូតតាំងពីនោះមក ជាដើម ។

## ២–អារ្យធម៌សម័យអង្គរ

លុះជាប់ពីសតវត្សទី ៨ មក ស្ថាបត្យកម្មធំៗរបស់យើងក៏លេចធ្លោឡើង, របៀបរៀបចំស្រុកទេសក៏បោះតែកើនជាលំដាប់ ។ របបជីវភាព (Mode de vie ) ក៏ផ្លាស់ប្តូរទៅរកវិត្ថារភាពសមសួន ដូចមានរូបបញ្ជាក់ជា

តាំងនៅជញ្ជាំងប្រាសាទអង្គរធំទុកជាជានស្រាប់ ៗ តែក ជាងគ្រប់វិស័យនៃអារ្យធម៌ បានចំរើនឥតឧបមាស្មើៗគ្នា រហូតបានទៅជាអារ្យធម៌ជាតិខ្លាំងពូកែមួយ នៅចុងបូព៌ា ប្រទេសនេះ ។ អាស្រ័យហេតុនេះហើយ បានជានៅ សម័យនោះ មានជាតិថ្មីៗ នៅជិតខាងយើង បានចម្លង ប្រឌិតយកបែបអារ្យធម៌យើង ទៅធ្វើជាអារ្យធម៌ជាតិគេ ជាបន្តទៅផង ។

រយៈវេលានេះមានពេលយូរយារដែរ គឺតាំងពី សតវត្សទី ៨ ដល់ទី ១៥ ដែលត្រូវលះបង់ក្រុងអង្គរ ។ សម័យកាលនេះ អ្នកប្រវត្តិសាស្ត្រសំគាល់ថា ជាសម័យ រុងរឿងបំផុតរបស់ខ្មែរនៅលើប្រជាយសុវណ្ណភូមិនេះ ។

## ៣–អារ្យធម៌សម័យកណ្ដាល

សម័យកាលនេះ យើងរាប់ពីសតវត្សទី១៥ រហូត

មកដល់ទី ១៩ នៃគ្រិស្តសករាជ ។ គ្រានេះប្រវត្តិសាស្ត្រ
ប្រាប់យើងថាស្រុកទេសកើតវិការដោយសង្គ្រាមទន្ទ្រាន
ស្រុកមកពីបច្ចាមិត្រឯក្រៅៗផង និងមានសង្គ្រាមក្នុង
ស្រុក រុករួនខ្លះទៀតផង នាំឲ្យផ្កាអារ្យធម៌ធ្លាក់ចុះរុះ
រោយទៅវិញ ។ កាលណាមានអាសន្ន ឬ កោលាហល
យ៉ាងនេះ ផ្នែកវប្បធម៌ក្ដី ផ្នែកសង្គមធម៌ក្ដី ដែលជាមែក
ធំៗ នៃអារ្យធម៌យើងនោះ ក៏វិលត្រឡប់ជាស្ងប់ស្ងៀម
គឺពុំលូតលាស់ឡើងថែមទៀតទេ មិនតែប៉ុណ្ណោះ ថែម
ទាំងចន់ចុះអន់ថយក្រោយទៅវិញទៀតផង ត្បិតអ្នក
ស្រុកអ្នកប្រទេសគ្មានឱកាសនឹងកសាង ហើយបើសាង
បានហើយក៏គ្មានលទ្ធភាពនឹងរក្សាគ្រង ទុកឲ្យគង់វង្សបាន
ដោយសារតែចលាចលបុករុកជារឿយៗ ឯអ្នកទន្ទ្រាន
ទឹកដីមកពីក្រៅនោះ ក៏ព្យាយាមដឹកជញ្ជូនប្រមូលយក

ក្បួនខ្នាតអារ្យធម៌យើងទៅ ហើយលួចបម្លងពុម្ពអារ្យ

ធម៌គេឲ្យស្រោចស្រពប្រាបមកដែនដីយើងទៀតផង ។

ហេតុនេះ យើងមិនត្រឹមតែបំបាក់ ដោយរក្សាទ្រព្យ

មតិកអារ្យធម៌ខ្លួនប៉ុណ្ណោះទេ, ថែមទាំងពិបាកទប់ទល់

នឹងកំឡាំងអារ្យធម៌ក្លាយរបស់គេ ចូលមកជ្រៀតជ្រែក

ថែមទៀតផង ។ សន្និដ្ឋានទៅឃើញថា ក្នុងសម័យ

កាលនោះ ជាពេលគ្រោះដោកគ្រោះដាំ ធ្លាក់មកលើ

អារ្យធម៌យើង នាំឲ្យមិនបានចំរើនលូតលាស់ ។

## ៤–អារ្យធម៌សម័យបច្ចុប្បន្ន

សម័យនេះ យើងពុំបាច់រៀបរាប់ច្រើនទេ ព្រោះជា

រឿងដែលយើង-គេទាំងអស់គ្នា ធ្លាប់បានឃើញបាន

យល់នឹងភ្នែក សព្វៗខ្លួនហើយ ។

ប៉ុន្តែគួរសង្កេតតែមួយចំណុចគឺ ៖ ត្រង់សម័យ

កាលនេះមានចែកជាពីរភាគគឺ ៖ សម័យអាណាព្យាបាល បារាំង និងសម័យឯករាជ្យ ។

ក្នុងសម័យអាណាព្យាបាលបារាំង អារ្យធម៌យើងត្រូវទទួលការគ្របដណ្តប់អំពីអារ្យធម៌បស្ចិមប្រទេស ដូចមានទំនៀមទម្លាប់ផ្សេងៗ ក្នុងអាពាហ៍ពិពាហ៍ ក្នុងសុជីវធម៌ ក្នុងគ្រឿងអលង្ការ ជាដើម ដែលខ្មែរនិយមជាប់ដល់សព្វថ្ងៃ ។ ដើមហេតុដែលនាំឲ្យយើងទទួលអារ្យធម៌ពីបស្ចិមប្រទេសដូច្នេះ ព្រោះកាលនោះ យើងទើបតែឆ្លងផុតវិបត្តិពីមុនមក ដូចយើងអធិប្បាយក្នុងវគ្គទី ៣ រួចមកហើយខាងលើ ។ ម្យ៉ាងទៀតអារ្យធម៌បស្ចិមប្រទេស ជាអារ្យធម៌ខ្លាំងក្លា អាចមានកំឡាំងគ្របដណ្តប់ទៅលើអារ្យធម៌នៃជាតិដទៃ ហើយដូចជាអារ្យធម៌ខ្មែរយើងកំពុងវិបត្តិផង អាការៈខាងទន់របស់

យើងក៏លំទុនទៅភ្លាមទៅ ឧបមាដូចមនុស្សដែលទើបតែងើបពីឈើពុំទាន់មានកំឡាំងពលំល្អ កាលបើត្រូវគេប្រទាញទៅខាងណាក៏ទន់ទៅតាមគេយ៉ាងឆាប់រហ័ស ៗ ប៉ុន្តែទោះជាយ៉ាងណាក្តី ក៏ជនជាតិខ្មែរយើង មិនលះបង់គ្រឿងដំណែលខ្លួនឲ្យអស់ឡើយ ហេតុនេះបានជាវប្បធម៌ខ្មែរនៅតែមានរូបជានិច្ច ។

ចំណែកសម័យឯករាជ្យវិញ ជាសម័យមានកំណើតថ្មី គឺការកសាងជាតិគ្រប់វិស័យ ចាប់ផ្តើមឡើងយ៉ាងឆាប់រួសរាន់បំផុត ដូច្នេះបានជាគ្រាន់តែប៉ុន្មានឆ្នាំ យើងរៀបចំវប្បធម៌យើងឲ្យរៀបរយសមរម្យ នឹងយសយើង ជាស្រុកឯករាជ្យពេញលេញ ។

សរុបសេចក្ដីទៅ ឃើញថាខ្មែរយើងមានវប្បធម៌មួយផ្ទាល់របស់ជាតិពិតប្រាកដណាស់ ដូចមានសំអាងទៅលើហេតុការណ៍ជាប្រវត្តិសាស្ត្រវែងឆ្ងាយដែលអធិប្បាយមកហើយនេះ ។

# សាខានៃអារ្យធម៌ខ្មែរ

បានជាជនជាតិនានាគេទទួលស្គាល់ថា ខ្មែរយើង មានអារ្យធម៌មួយដែរនោះ ដោយសារយើងមានកស្តុ-តាង នូវសាខាផ្សេងៗ នៃអារ្យធម៌ សំរាប់បង្ហាញគេ គ្រប់បែបយ៉ាង ដូចអារ្យធម៌របស់ជាតិនានាដែរ ។ អារ្យធម៌យើង ដែលចែកចេញជាសាខាធំៗ ពីរ គឺ វប្បធម៌ ១, សង្គមធម៌ ១ និងមានមែកធាងបន្ទាប់បន្សំ ចែកចេញទៅទៀតនោះ យើងអាចលើកយកមកបញ្ជាក់ បាន ដូចតទៅនេះ ៖

**ទីមួយ– វិស័យវប្បធម៌** (Domaine Culturel)

ក្នុង "វប្បធម៌" គេសង្កេតឃើញ ការបញ្ជាក់គ្រប់ ចំណុចដូចមានរៀបរាប់ហូរហែខាងក្រោមគឺ ចែកចេញ ជាបីផ្នែកធំៗ មាន ៖

១– អំពីការចេះដឹង (Connaissances)

ជាដំបូងឡើង ជនជាតិយើងរិះគិតបង្កបង្កើតអាការចេះដឹងផ្សេង ៗ សំរាប់ឲ្យឃើញថាជាអារ្យធម៌មួយនឹងគេឡើង ដោយមានបែកចេញជាជានតូច ៗ ទៀតគឺ៖

ក- ជំនឿផ្សេង ៗ (Croyances). តាំងពីដើមរហូតមក ខ្មែរយើងបង្កើតជំនឿសម្រាប់ជាមធ្យោបាយរួបរួមសាមគ្គី ព្រោះគេយល់ថា កាលណាមនុស្សមានជំនឿដូចគ្នា គេនឹងចេះរាប់រកគ្នាបានជិតស្និទ្ធ ។ ជំនឿដំបូងរបស់ជនជាតិយើង ដូចជា ការជឿខ្មោចបិសាចនៅដើមឈើធំ ចងបត់ព្រឹក្ស និងព្រះភូមិរក្សាស្រុក ជាដើម ។

១. បើគេជឿខ្មោចដួរចំបួរជាមួយគ្នា គេតោងរាប់រកគ្នា, បើគេទៅគោរពដើមឈើជាមួយគ្នា ក៏គេរាប់រកគ្នាកើតសាមគ្គីឡើង ។

ខ- លទ្ធិ (Religion) ដំបូងយើងបង្កើតលទ្ធិ

ប្រកាន់ខ្មោចផ្លូវដំបូងឲ្យមានលៀនច្រក់ រួចទៅយើង

បានចម្លងបែបមកពីប្រទេសគេខ្លះ ត្បិតយល់ថាក្នុងការ

គោរពលទ្ធិណាមួយរួមគ្នានាំឲ្យមនុស្សបេះបង់សាមគ្គីគ្នា

ហើយក្នុងលទ្ធិនីមួយ ៗ នោះ មានគោលគំនិតសម្រាប់

ជាមទពិចារណាច្រើនផង ទៅថ្ងៃក្រោយ ដូចជាលទ្ធិ

ព្រាហ្មណ៍ជាដើម ។

ម្ល៉ោះហើយទើបគេនិយមលទ្ធិព្រាហ្មណ៍ ហើយ

ទាញយកលទ្ធិនេះ មកលាយជាមួយជំនឿចាស់របស់ខ្លួន

ដែលមានស្រាប់ពីមុនមកផង ។

គ- សីលធម៌ (Morale).- ពិតមែនតែអាឡឹធម៌

ដំបូងពុំបានចងក្រងជាក្បួនទេ តែមានការណែនាំខាង

សីលធម៌ក្នុងជំនឿ ក្នុងទម្លាប់ ផ្សេង ៗ គ្នា ដូចជាការ

ប្រាប់ប្រាមក្មេងកុំឲ្យដេកខ្ពស់ជាងចាស់ខ្លាចយាយចាស់ចាក់ទឹកបាយលើ , កុំស៊ីបាយឲ្យរុះខ្ទះខ្ទាយ ព្រះមេប្រ-ទេច , កុំលួចរបស់គេការល្មួយដៃនិងមានពាក្យទំនៀមជាច្រើនទៀតសម្រាប់ឲ្យដំបូន្មានដល់ក្មេង ។ បានជាបង្កើតឲ្យមនុស្សជឿ ហើយធ្វើឲ្យត្រូវតាមមិនហ៊ានខុសដូច្នេះ ត្បិតនិយមទៅតាមផ្នត់គំនិតមនុស្សជាន់ដើម ដែលពុំទាន់បេះយកស្មារតីរិះគិតជ្រៅជ្រះមកប្រើនៅឡើយ ។

ឃ- ទស្សនវិជ្ជា ( Philosophie ).– ក្នុងវប្បធម៌នៃជាតិនីមួយ ៗ ត្រូវតែមានទស្សនវិជ្ជាជាប្រដាប់សញ្ជឹងត្រិះរិះក្នុងវិចារណញ្ញាណ ហេតុនេះ បានជាដំបូងខ្មែរតែងភ្ជាប់គំនិតទៅក្នុងសិល្បៈ ក្នុងជំនឿ ក្នុងទំនៀមទាំងអស់ គឺថា បើធ្វើអ្វី ៗ សុទ្ធតែរកន័យក្នុងនោះសិនពុំព្រមធ្វើដោយគ្មានន័យឡើយ ។ បន្ទាប់មក យើង

ខិតខំបញ្ចូលទ្រឹស្តីព្រះពុទ្ធ ដែលជាគោលទស្សនវិជ្ជាធំបំផុតក្នុងលោក មកក្នុងអារ្យធម៌យើង តាំងពីពុទ្ធពិរិយារណ៍រហូតដល់ទំនៀមប្រពៃណីពុទ្ធនិយម ហើយដែលសព្វថ្ងៃទស្សនវិជ្ជានេះ ទទួលបាន: ខ្ពង់ខ្ពស់ក្នុងសន្តានចិត្តជនជាតិខ្មែរយើង ។

ង -វិទ្យាសាស្ត្រ (Sciences) – បើមើលតែបន្តិចបាក់ដូចជាមែកធាងសំខាន់នេះគ្មានក្នុងវប្បធម៌ជាតិយើងទេ តែបើសង្កេតឲ្យជ្រៅ យើងឃើញពីបុរាណកាល វិទ្យាសាស្ត្រខ្មែរមានសន្ទុះខ្លាំងណាស់ក្នុងតាំងនៅក្នុងបច្ចេកទេសនៃស្ថាបត្យកម្មប្រាសាទអង្គរ ដូចជាការគូរផែនទីបាក់ជោ ការលើកផែនថ្ម ការស្មូរឆ្នើថ្មឆ្លាក់ថ្ម និងការធ្វើបារ៉ែត ចំក្បឹពេញប្រាសាទ ។ល។

២– អំពីការផ្សាយ (Publication-Diffusion):

កាលណាបន្តបង្កើតបានជាចំណេះចេះដឹងរួចហើយ គេតែងមានមធ្យោបាយសម្រាប់ផ្សាយ នូវចំណេះទាំងនេះទៀត គឺមាន ÷

ក- អក្សរសិល្ប៍ (Littérature).— អក្សរសិល្ប៍នេះ ពោលសំដៅគោលមតិខ្លួនទៅ ដែលកត់ត្រាអំពីចំណេះវិជ្ជា ហើយផ្សាយចេញតាមវិធីតាក់តែងច្រើនបែប យ៉ាងគឺ ÷ តាមការចងចាំតៗគ្នា ការនិទានប្រាប់គ្នា ការសំដែងតាយវិការ ការសរសេរ ការគាន ។ល។ ដូច្នេះ គ្រប់ចំណុចក្នុងវប្បធម៌ តែងប្រមូលផ្តុំនៅក្នុងអក្សរសិល្ប៍នេះជានិច្ច ហេតុនេះបានជាគេរមែងចាប់អារម្មណ៍ណាស់ លើអក្សរសិល្ប៍ កាលណាគេចង់យល់ច្បាស់នូវអារ្យធម៌របស់ជនជាតិណាមួយៗ ផែកឯនេះមានច្រើនណាស់នៅក្នុងវប្បធម៌យើង ដូច

ជារឿងព្រេង រឿងប្រឌិត រឿងបែបឧបទេស ( Didac-tique ) ។ល។ ដែលមានចារទុកក្នុងសាស្ត្រា ឬក្រាំង គម្ពីរ ក្បួនខ្នាតផ្សេង ៗ ផង ។

ខ- សិល្បៈ ( Arts) សិល្បៈជាការសំដែងចេញនូវមនោសញ្ចេតនា និងលក្ខណៈចរិយារបស់មនុស្ស ហើយដែលកើតឡើងព្រមគ្នាជាមួយមនុស្សដែរ ។ ខ្មែរយើងបានយកចិត្តទុកដាក់បំផុត តាំងពីកើតជាជាតិមួយនឹងគេមក ដូចមានភស្តុតាងនៅក្នុងក្បាច់ចាស់ ៗ របស់អ្នកស្រុកដាន់ដើម មានគ្រឿង កាំស្នែងទនេក្យាន កាំគោះអង្រែ និងបទបែបទំនុកច្រៀង ឬក្បួរក្បាច់របនាជាដើម ។ ក្រោយដែលបានទទួលឥទ្ធិពលអារ្យធម៌ពីបរទេសខ្លះមកទៀត សិល្បៈយើងក៏រីកចំរើនជាលំដាប់ រហូតដល់បានឈ្មោះថាជា សាសន៍សម្បូណ៌ទៅដោយសិល្បៈ ក្នុង

ចំណោមប្រទេសទាំងឡាយនៅភូមិភាគជុំវិញ ។

គ-អក្សរ-ភាសា ( Ecriture-Langage ) អក្សរ និង ភាសា មានមុខងារផ្សាយនូវវប្បធម៌សំខាន់ជាងគេ ព្រោះថា ជាដំបូង នឹងឲ្យជនជាតិខ្លួន ក្រេបជញ្ជក់នូវចំណេះវិជ្ជា ដែលមានមកហើយនោះបាន ទាល់តែបង្កើតពាក្យសំដីឲ្យមានគ្រប់គ្រាន់ និងធ្វើជាតួអក្សរប្រើប្រាស់បានគ្រប់សព្វផង ទើបការផ្សាយចំណេះនោះ មានឯកភាពល្អ ព្រមទាំងទទួលផលបានជាទីពេញចិត្ត ដោយហេតុអក្សរនិងភាសានេះ អាចពលដាលទៅឆ្ងាយគ្រប់ទិសទីឥតកំបាំងឡើយ ។ អាស្រ័យហេតុនេះ បានជាមនុស្សដើមខ្មែរយើង បានបង្កើតពាក្យនិយាយប្រស្រ័យទាក់ទងគ្នាបានតាំងពីមុនអារ្យធម៌ឥណ្ឌា ចូលមកស្រុកយើងទៅទៀត លុះក្រោយមក ទើបបង្កើតបានជា

អក្សរសម្រាប់សរសេរផ្សាយ នូវសិរីនិងភាសានេះឡើងបាន

ពេញលេញ ដែលអាចកត់ត្រាទុកជាលក្ខណ្ឌបាន ។

ឃ-ពត៌មាន ( Information)— វិធីផ្សាយតាមរយៈ

ពត៌មាននេះ ពីដើមមក ពុំសូវមានឥទ្ធិពលប៉ុន្មានទេ

ព្រោះពត៌មានដំណឹងទៅណាមកណា បានតែតាមរយៈអ្នក

ពោល អ្នកនិយាយដោយមាត់ ប៉ុន្តែ នៅបច្ចុប្បន្ននេះ

ពត៌មាននៅប្រទេសយើង ក៏រីកចំរើនដូចគ្នានឹងពត៌មាន

នៅប្រទេសនានាដែរ ដូចជាសៀវភៅទស្សនាវដ្ដី ទស្សនាវដ្ដី

សារពត៌មាន វិទ្យុ ទូរទស្សន៍ ។ល។

៣-អំពីការអនុវត្តន៍ ( Application ) :

ក្រោយពីការបង្កើត និងការផ្សាយនេះហើយ គេ

ត្រូវតែប្រើការអនុវត្តន៍ នៅមានការអនុវត្តន៍នៃអារ្យធម៌

គុណសម្ផុមជាតិទៀត ។ វិធីអនុវត្តន៍នេះ គេរកឃើញ

ជាតើគេអនុវត្តិតាមផ្លូវណាខ្លះនោះ គឺ ៖

ក-ទំនៀមទំលាប់ ( Mœurs et coutume )កាល

បង្កើតបានជាជំនឿហើយ ក៏ផ្សាយចេញបានជាការចូល

ចិត្តអ្វីមួយឡើង ៗ អ្នកស្រុកនាំគ្នាយកគោលគំនិតប្រ

ទ្ធស្ដីនោះមកទម្លាប់មកប្រើក្នុងជីវភាពរបស់ខ្លួន រហូត

ទៅជាទំនៀមជាប់លាប់ ពុំងាយនឹងរលុបរលាយបាន

ឡើយ ដូចជាពិធីដែលគេធ្វើក្នុងការប្រកក់ទារក,អាពាហ៍

ពិពាហ៍, បុជាសព ជាដើម គឺជាទំនៀមទម្លាប់នេះទៀត

ដែលជាការផ្ដិតជាប់នូវរូបភាពអារ្យធម៌ ទៅក្នុងការរស់

នៅរបស់អ្នកស្រុកតាមញាតិទៅ តាំងពីទីក្រុងដល់ស្រែ

ចំការ ។

ខ-ការសិក្សា-អប់រំ(Enseignement-Education )

ជនជាតិយើងយកចិត្តទុកដាក់ណាស់ ក្នុងកិច្ច

បង្ហាត់បង្រៀននិងណែនាំគ្នាឲ្យបានល្អប្រសើរៗ គេរកឃើញដានជាច្រើនបង្ហាញឲ្យយើងដឹងថាការសិក្សាកើតមានក្នុងអារ្យធម៌យើង . បន្ទាប់ពីការកើតមានចំណេះនិ· មួយៗក្នុងអារ្យធម៌ដែរ ។ បានសេចក្ដីថា សា.ណា ចំណេះវិជ្ជាណាមួយកើតឡើងបានភ្លាម មានការសិក្សាភ្លាមមួយរំពេចនោះដែរ ហើយបើឃើញមានឧត្តមគតិណាប្រពៃ គេក៏ត្រង់ត្រាប់អប់រំខ្លួនឯងឬអ្នកជិតខាង នៅពេលភ្លាមនោះដែរ ប៉ុន្តែការសិក្សានិងអប់រំជំនាន់ដើម ច្រើនធ្វើតាមពាក្យទូន្មានផ្ទាល់មាត់ ឬតាមសាស្ត្រាស្លឹករឹតនៅដោយវត្តអារាមផ្សេង ៗ ។ នៅគ្រាសព្វថ្ងៃ ការសិក្សា-អប់រំ បានឡើងដល់ថ្នាក់ទី ១ នៃវប្បធម៌យើង ដោយមានប្រើប្រាស់វិធីសាស្ត្រសម័យថ្មី ត្រឹមត្រូវផង ។

គ–ល្បែង កីឡា (Jeux-Sport ),—ជាអង្វែនហើយ

ជនជាតិខ្មែរ បានបង្កើតល្បែងច្រើនបែបច្រើនយ៉ាង សម្រាប់លំហែការអផ្សុក និងបង្ហាត់ខាងកាយសម្បទាឲ្យបានមាំទាំល្អ ល្បែងទាំងនេះនៅពេលបច្ចុប្បន្នខ្លះក៏ក្លាយទៅជាកីឡាសំខាន់ៗដោយមានបញ្ចូលថែមនូវវិធីសាស្ត្រទំនើបថ្មីៗ ល្បែងដែលយើងស្គាល់បានជាមានមកយូរហើយនោះ ដូចជា ល្បែងទាញព្រ័ត្រ ចោលឈូង ទល់អង្រែ វាយកូនគោល ទាត់សី ប្រដាល់ បោកចំបាប់ គុនដំបង ។ល។ ហើយដែលសព្វថ្ងៃនេះ មានខ្លះប្រែក្លាយទៅជាកីឡាយ៉ាងសុទ្ធសាធ ។

## ទីពីរ_ ផ្នែកសង្គមធម៌ (Domaine Social)

កាលណាផ្នែកវប្បធម៌កើតមានសព្វគ្រប់ឡើងហើយ-ខាងសង្គមធម៌ក៏ត្រូវតែលូតលាស់តាក់តែងឡើងជាបន្ទាន់ដែរ ប៉ុន្តែបើមើលតាមប្រវត្តិសាស្ត្រ យើងឃើញថាក្នុងពេលដំបូង សង្គមធម៌ខ្មែរក៏ចំរើនណាស់ដែរ តែនៅសម័យត្រូវធ្លាក់ខ្លួនដោយអំណាចសង្គ្រាម យើងក៏បាត់បង់ស្ទើរតែអស់ ។ មកដល់នេះយើងទើបតែសាងឡើងវិញនៅពេលបានឯករាជ្យហើយ ដូចជា ៖

### ១– អំពីសង្គមវិជ្ជា ( Sociologie )

គឺជាបែបបទសិក្សាសម្រាប់ពិនិត្យសង្កេតផង និងប្រតិបត្តិផង នូវគម្រោងការខាង ៖

ក- សេដ្ឋកិច្ច(Economie ).- គោលគឺការស្វែងរកផលិតផល ដើម្បីផ្គត់ផ្គង់សង្គមជាតិនូវភោគទ្រព្យសម្រាប់ទ្រទ្រង់ប្រទេស បើនិយាយឲ្យបំគឺធនធានជាតិមានពីធនធានធម្មជាតិរហូតដល់ការស្ថាបនាថ្មីៗទៀត ។

ខ-សង្គមកិច្ច ( Sociale) .ការរៀបចំឲ្យមានរបៀបរៀបរយ និងធមធ្យោបាយក្នុងអាជីវកម្មផ្សេងៗនៃមនុស្សក្នុងប្រទេស ព្រមទាំងឲ្យមានការសុខស្រួលបានទូលំទូលាយក្នុងជីវភាពជន ដូចជាឲ្យមានមន្ទីរព្យាបាលជម្ងឺ, មានការទាក់ទងគ្នាបានស្រួល មានគ្រឿងបរិភោគ-ឧបភោគគ្រប់គ្រាន់ ។ល។

គ-នយោបាយ( Politique )- ល្បិចកិច្ចកលគ្រប់បែបយ៉ាងសម្រាប់ដោះស្រាយ បញ្ហាជាតិ នឹងរិះរកផល ទាំងខាងផ្លូវចិត្ត-ផ្លូវសម្ភារៈ ផ្ដល់ឲ្យប្រទេសជាតិ

មានកិត្តិយស ដើម្បីឲ្យស្របនឹងសេចក្តីត្រូវការចាំបាច់ ដោយមានភាពជាផែនការជាក់លាក់ សម្រាប់ធ្វើឲ្យបានថ្កុំថ្កើងទាំងក្នុងប្រទេស ទាំងកិត្តិយសឯក្រៅប្រទេស ។

ឃ- និតិសាស្ត្រ ( Juridique ).– ច្បាប់ទម្លាប់សម្រាប់ជាលក្ខខណ្ឌក្នុងការប្រតិបត្តិ នៃដំណើរជីវិតឲ្យបានយុត្តិធម៌ត្រឹមត្រូវល្អ សមរម្យជាប្រទេស ជាសញ្ជាតិក្នុងមហាសង្គមមួយ ។ ។. ច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ រដ្ឋធម្មនុញ្ញ ។ល។

២–អំពីសង្គមសម្ភារៈ( Equipement social )

នេះឯងជាចំណុចមួយ ខាងការផ្គត់ផ្គង់ជាប្រដាប់ប្រដា ប្លែបផែនដែលចែកចេញជា ៖

ក–ប្រដាប់ប្រដាប្រើប្រាស់( Instruments )–

ដូចយ៉ាងប្រដាប់ប្រើក្នុងគ្រួសារ មានសំពត់អាវជាដើម

ក្នុងកិច្ចការបង្កើនផលមានគ្រឿងៗ សព្វាហកម្មជាដើម ឬ ការរក្សាការពារសុខភាព មានឱសថជាអាទិ សំរាប់ជួយបំប៉នឲ្យសង្គមជាតិ មានសិរីភាពល្អគ្រប់គ្រាន់ ។

ខ - វិធីសាស្ត្រមុខបច្ចេកទេស (Technique ). - ជាបែបពត់ចាត់ឲ្យមានរបៀបបែបផែន ឬ កិច្ចការឯកទេសពិសេសដោយឡែកខាងចំណេះអ្វីមួយ ដូចជាគ្រឿងចក្រ គ្រឿងយន្តជាដើម ដែលសង្គមជាតិនានានៅបច្ចុប្បន្នកាលនេះ កំពុងតែត្រូវការណាស់ ។

គ - របររកស៊ី-វិជ្ជាជីវៈ (Métiers). - មុខងារដោយឡែកៗពីគ្នាសម្រាប់ចែកផលឲ្យមនុស្សរស់នៅបានស្រួលទីទៃៗ តាមការប៉ិនប្រសប់របស់ខ្លួនដោយទទួលផលអំពីមុខរបរទាំងនោះ ព្រោះបើគ្មានមុខរបរចែកផលមនុស្សគ្រប់គ្នាទេ ក៏នៅពុំទាន់មានការសម្បូណ៌សប្បាយ

ដែរ ។

៣-អំពីសង្គមនិម្មាណ ( Structure sociale ).-

ត្រង់នេះជាការចែកនាទីគ្នា ដោយក្រុមៗ ដើម្បីកសាងជាក្រុម-ជាពួកសមាគមមួយៗ សម្រាប់ចាត់ការតាមកម្លាំង កសាងជាតិដែលចែកជា ៖

ក- ស្ថាប័ន (Institutions). ដែលហៅថាស្ថាប័ននេះគឺជាវិធីរួបរួមកំឡាំងគ្នា ដែលគេរៀបចំឲ្យមានជាអង្គការទទួលមុខការគិតខាងវឌ្ឍនធម៌ជូនជាតិគ្រប់វិស័យ តាមការចូលចិត្តនៃជនជាតិមួយពួកៗ មួយក្រុមៗ ដូចជាអង្គការខាងសង្គមកិច្ច, វប្បធម៌ (មានសមាគម);អង្គការខាងនយោបាយ (គណៈបក្ស-ក្រុម-ចលនា), អង្គការខាងសេដ្ឋកិច្ច ( មានសហករណ៍-ក្រុមហ៊ុន ) ជាដើម ។

១-វណ្ណវិភាគ (Division Sociale)- របៀបបែកងារសក្តិមនុស្សទៅតាមក្រុមញាតិ តាមមុខងារ តាមធនធាន ។ល។ ដែលមនុស្សពួកនីមួយៗ និយមរាប់រកតាមការត្រូវអធ្យាស្រ័យ ។ ប៉ុន្តែ ការចំរើននៃមនុស្សតែងមានរបៀបប្រែប្រួលក្នុងវណ្ណវិភាគនេះច្រើនដែរ ។

# ប្រភពនៃអារ្យធម៌ខ្មែរ

យើងធ្លាប់យល់មកហើយ ដែលសំគាល់ពេញលេញថា «អារ្យធម៌» មួយបាន ព្រោះមានលក្ខណៈគ្រប់គ្រាន់បញ្ជាក់ឲ្យឃើញថា៖ ការបេះដូងផុសចេញមកពីជាតិនោះៗដោយខ្លួនឯងច្បាស់ប្រាកដ សម្រាប់ជាគ្រឿងសម្គាល់នូវចំណេះវិជ្ជាបុលក្ខណៈសេចក្ដីចំរើនរបស់ជាតិៗ

អារ្យធម៌ខ្មែរយើងមានរូបរាងឡើងបន្តិចម្ដងៗ មកជាអន្លើនហើយ បើគិតតាមប្រវត្តិសាស្ត្រយើងឃើញថា អារ្យធម៌ខ្មែរ ចាប់ផ្ដើមមានមក តាំងពីមុនគ្រិស្តសករាជទៅទៀត ។ អារ្យធម៌ដំបូងនោះ គឺជាកម្រងការបេះដូងផ្សេងៗមាន ភាសា ភ្លេង ចំរៀង ទំនៀមៗលៗ របស់ជនជាតិដើម គឺកុលសម្ពន្ធ ឬរដ្ឋវាសី(Autochton es)ដែល

រស់នៅស្រាប់លើផែនដីខ្មែរយើងដូចជា គួយ សំរែ ពារ ព្នង ហើយដែលសព្វថ្ងៃពិតមែនតែពួកនេះ នៅជាអ្នកនៅដោយព្រៃហាក់ដូចពុំសូវមានវឌ្ឍនធម៌ តែជនជាតិទាំងនេះបានទុកកេរ្តិ៍អារ្យធម៌ឲ្យយើងច្រើនរួចមកហើយ ។

ប៉ុន្តែ ក្រោយពេលដែលកសាងបានជារូបរាងហើយ អារ្យធម៌យើងក៏ត្រូវទទួលឥទ្ធិពលខ្លះៗ អំពីអារ្យធម៌ជនជាតិផ្សេងៗ ដែលធ្លាប់ចូលមកអាស្រ័យនៅក្នុងស្រុកយើង ។ ព្រោះជាធម្មតា មនុស្សបុរាណឬសព្វថ្ងៃ សុទ្ធតែត្រូវការបញ្ចូលបន្ថែម ការចេះដឹងពីគេឯងយ៉ាងនេះ ដូចមានសេចក្តីបញ្ជាក់តទៅ អំពីប្រភពដែលចូលមក ៖

## ក– ប្រភពឥណ្ឌា

អារ្យធម៌ឥណ្ឌាជាអារ្យធម៌ខ្លាំងក្លាព្រោះមានមកក្នុងកាលណាចក្រឥណ្ឌាជាច្រើនសតវត្សមុនគ្រិស្តសករាជបាន

នូវចូលក្នុងប្រទេសយើង តាមរយៈព្រាហ្មណ៍កៅណ្ឌិន្យ កាលពីសតវត្សទី១នៃគ្រិស្តសករាជ ហើយបានផ្សាយពាស ពេញលើប្រទេសយើងតាំងពីកាលនោះមកដូចជាភាសា សំស្ក្រឹត លទ្ធិសាសនា និង ទំនៀមជាច្រើន ដែល ក្លាយទៅជាទំនៀមទម្លាប់សមញ្ញ របស់អ្នកស្រុកយើង ដោយហេតុពពួកព្រាហ្មណ៍ទាំងនោះ បានឡើងជាក្សត្រ គ្រងរាជ្យលើទឹកដី ។

## ខ-ប្រភពចិន

តាមការសង្កេត អារ្យធម៌ចិនបានចូលមកកាន់ ស្រុកយើងជាប់ពីសតវត្សទី ៣ ឬទី ៤ តាមរយៈពពួក អន្តោប្រវេសន៍ជាតិចិនដែលនាំទំនិញចេញចូល ហើយ ខ្លះក៏មកតាំងទីលំនៅជាប់លាប់នឹងស្រុកយើង ព្រមទាំង មានប្រពន្ធកូនពង្រីកគ្រួសារ ហើយបង្អាត់ ហ៊ីកហ៊ីន

អារ្យធម៌ចិនតាមរយៈក្រុមញាតិរបស់ខ្លួនបន្តិចម្តងៗ ជាពិសេស គឺទំនៀមទម្លាប់សម្រាប់ប្រតិបត្តិកិច្ចការរស់នៅប្រចាំថ្ងៃនិងជំនឿផ្សេងៗច្រើនទៀត ។

គ- ប្រភពបស្ចិមប្រទេស

អារ្យធម៌នេះ បានហូរចូលមកស្រុកយើង នៅចុងសតវត្សទី ១៩ តែមានឥទ្ធិពលខ្លាំងក្លាណាស់ព្រោះជាប់មកជាមួយពួកអ្នកមានអំណាចធ្វើជាអាណាព្យាបាល ប្រទេសយើង ។ ហេតុនេះ ទើបមានសន្ទុះយ៉ាងរហ័សនាំឲ្យយើងរើសយកសុជីវធម៌ សំលៀកបំពាក់ និងបែបបទសិល្បៈខ្លះៗពីពួកនេះ ហើយកាន់តែរីកចំរើនឡើងរហូតសព្វថ្ងៃនេះ ។

ឃ-ប្រភពផ្សេងៗ

ដែលហៅថាប្រភពផ្សេងៗគឺដើមកំណើតមកពី

ខ្លះនៃអារ្យធម៌យើង ឆ្លងមកពីស្រុកជិតខាង ឬស្រុកទេស

ដែលធ្លាប់បានប្រាស្រ័យគ្នាកាលពីជំនាន់ដើម ដូចជាជាតិ

ជ្វា ម៉ាឡេ មន សៀម លាវ យួន ជាដើម ។ ការឆ្លង

ចូលពីក្រៅនេះ ច្រើនតែជាពាក្យសំដី ម្ហូបនៀមបន្តិច

បច្ចេកវិជ្ជាការ សាមញ្ញ ។ ផលដែលឆ្លងចូលមកនេះ

ជាថ្វីដែលជនជាតិទាំងនេះ បានក្រោយយកផលពីយើង

ទៅបំប៉ិនអារ្យធម៌គេក្រាស់ក្រែលដែរ ។

ដូច្នេះ យើងបញ្ជាក់បានថា ទោះបីជាអារ្យធម៌

កំណើតដើមរបស់យើងត្រូវទទួលឥទ្ធិពលអារ្យធម៌ពីទិសនា

នាច្រើនប្រភពដូចពោលមកហើយមកបន្ថែមផងក៏ដោយ

ក៏យើងនៅតែមានលក្ខណៈមួយជាលក្ខណៈជាតិយើងឥត

ឲ្យបាត់បានឡើយ ហើយអារ្យធម៌នានានោះគ្រាន់តែជា

វត្ថុសំរាប់ធ្វើឲ្យអារ្យធម៌ដើមរបស់យើង រឹតតែមាន

ទ្រង់ទ្រាយល្អឡើងប៉ុណ្ណោះ ។ហេតុនេះទើបយើងទទួលស្គាល់បានថា ខ្មែរមានអក្សរធម៌មួយជាក់ប្រាកដ របស់ខ្លួនពុំមែនទើបតែយកបែបតាមគេទេ ហើយកើតសំណល់អក្សរធម៌ដើមនោះ អ្នកប្រាជ្ញសព្វថ្ងៃទទួលស្គាល់គ្រប់គ្នាឱ្យឈ្មោះថាអក្សរធម៌អូស្ត្រូ-អាស៊ី (Austro-Asiatiques) ដែលមានកំណើតដើម នៅលើដែនដីនានា ជាកោះ ជាជ្រោយ នៅតាមសមុទ្រប៉ាស៊ីហ្វិក ដែលផ្ទុយឆ្ងាយពីអក្សរធម៌ឥណ្ឌូ-អឺរ៉ុប (Indo-Européennes) ដែលមានកំណើតនៅឥណ្ឌា និងអឺរ៉ុប ។

# គោលនិយមនៃអារ្យធម៌ខ្មែរ

ក្នុងអារ្យធម៌ខ្មែរ បើផ្តេញដោយសន្និកទៅជាពួកជាក្រុមតាមគោលនិយមផ្សេងៗគ្នានោះ គេអាចចែកចេញបានជាបួនផ្នែក ឬ បួនចលនា ដូចតទៅ ៖

១–ព្រហ្មនិយម (Brahmanisme)

២–ពុទ្ធនិយម (Bouddhisme)

៣–ខេមរនិយម (Khmerisme)

៤–បរទេសនិយម (Influence étrangère)

បានជាគេកប់បានថា អានុភាពនៃគោលនិយមទាំងនេះ ជាគោលនិយមនៃអារ្យធម៌យើងបាន ព្រោះក្នុងវប្បធម៌ខ្មែរ បានបង្ហាញយ៉ាងច្បាស់នូវការជិតជាប់លាយឡំដោយទំនៀមនៃឥទ្ធិពលទាំងនេះជាដរាប ដូចមាន

សេចក្តីអធិប្បាយតទៅនេះ ÷

១-ព្រាហ្មណ៍និយម

គោលនិយមនេះបានបង្កើតវប្បធម៌ខ្មែរឲ្យដើរស្លូលទៅតាមទម្លាប់នៃលទ្ធិព្រាហ្មណ៍ ដូចជាការបោះនិងការដោះស្រាយផ្សេងៗ ក្នុងបញ្ហាវប្បធម៌ និងសង្គមធម៌ស្ទើរសឹងតែយកគំនៀមព្រាហ្មណ៍មកផ្សំបញ្ចូលជាដរាប ។ មិនតែប៉ុណ្ណោះ បលនានេះបានជ្រាបចូលក្នុងសន្តានចិត្តខ្មែរគ្រប់ៗ គ្នា តាំងពីសម័យដែលខ្មែរយើងនិយមរាប់អានលទ្ធិព្រាហ្មណ៍ពីសតវត្សទី ១ ដល់ទី ១៤ នៃគ្រិស្តសករាជ ។

២-ពុទ្ធនិយម

ពុទ្ធនិយមបានមកផ្លាស់វេនពីព្រាហ្មណនិយម ចាប់តាំងពីសតវត្សទី ១៣ នៃគ្រិស្តសករាជ គឺជាពេលដែល

ខ្មែរបុរាណគោរពកាន់តាមលទ្ធិព្រាហ្មណ៍ មកពុទ្ធសាស-
នាវិញ ។ នាំឲព្រះពុទ្ធបានជ្រួតជ្រាបចូលមកក្នុង
សន្តានចិត្តខ្មែរគ្រប់ៗគ្នាសព្វជាន់ថ្នាក់ បណ្តាលឲ្យខ្មែរយើងជ្រើស
រើសយកទស្សនៈរបស់ព្រះពុទ្ធ មកធ្វើជាការផ្ដួចផ្ដើមក្នុង
វប្បធម៌ខ្មែរ ។ ដូច្នេះ បញ្ហាគ្រប់បែបក្នុងអាត្មាធម៌
បលនានេះសំអាងយកគោលគំនិតព្រះពុទ្ធ មកដោះនិង
ដោះស្រាយទាំងអស់ ដូចជាការជឿកម្ម-ផល ជាដើម ។

៣-ខេមរនិយម-

គោលនិយមទី ៣ នេះ ប្លែកពីមុនៗ ដោយពុំបានយក
គោលពីលទ្ធិណា ឬសាសនាណាឡើយ គឺជាប្រវត្តិការ
ការណ៍ ដែលគេធ្លាប់ឃើញពិតជាក់ស្តែងក្នុងសង្គមជាតិ
ខ្មែរតែម្តង ។ គឺថា បើស្រុកទេសយើង ជួបប្រទះនឹង
បញ្ហាអ្វី ១ បញ្ហានោះក៏ជាការផ្ដួចផ្ដើមគំនិត កកើត

ជាបញ្ហាក្នុងវប្បធម៌និងសង្គមធម៌ជាតិឡើង ៗ ដូច្នេះ បញ្ហាដែលកើតក្នុងគោលនិយមនេះ ពុំមានរបៀបជាអច្ឆរិយ ( Merveilleux ) ឡើយ គឺសុទ្ធសឹងតែជាភាពពិតមែនទែនដែលស្របទៅនឹងលោកិយសច្ចៈ ( Réel ) ទាំងស្រុង ៗ

៤-បរទេសនិយម

គោលនិយមនេះ សំដៅដល់គោលគំនិតផ្សេង ៗ ដែលពុំស្របតាមលទ្ធិព្រាហ្មណ៍ សាសនាព្រះពុទ្ធ ឬជាទំនៀមសុទ្ធសាធរបស់ខ្មែរដែលធ្លាប់មានមក ៗ ប្រទេសយើង ទើបតែមានគោលនិយមនេះកើតឡើង ក្នុងរាជ ដែលប្រទេសខ្មែរត្រូវធ្លាក់ខ្លួនក្រោមគ្រា ហើយបរទេសនាំយកគោលគំនិតពីស្រុកគេមកផ្សាយបញ្ចូល ៗ ប៉ុន្តែគោលនិយមនេះមានឥទ្ធិពលខ្លាំងក្លាច្រើនណាស់ ក្នុង

ពេលបច្ចុប្បន្ន ព្រោះមនុស្សទូទៅក្នុងសាកលលោក ច្រើនចូលចិត្តគោលនិយមបែបនេះ ។ សព្វថ្ងៃគេឃើញ នៅសល់គោលនិយមនេះពាសពេញដូចជាខាងសុជីវធម៌ សំលៀកបំពាក់ សិល្បៈរាំរែក . . . ។ ល ។

ឥទ្ធិពល នៃគោលនិយមទាំងបួនយ៉ាងនេះ បានចូល ជាប់ក្នុងអារ្យធម៌ខ្មែរទាំងមូល នឹងដកប្រឡេះចេញគោល ណាមួយក៏ពុំបាន ព្រោះសព្វថ្ងៃយើងនិយមរាប់ថា ជា អារ្យធម៌ផ្ទាល់របស់យើង ហើយរលាយចូលក្នុងទំនៀម ទម្លាប់រស់នៅ ជាអចិន្ត្រៃយ៍ ទៅហើយផង ។

# អំពីភាសាខ្មែរ

## ក. សេចក្ដីផ្ដើម.–

ពាក្យ «ភាសា» ក្លាយមកពីសំស្ក្រឹត ប្រែថា សំដី ឬការពោលបញ្ចេញ ឬការសំដែងកាយវិការ ឲ្យយល់ន័យ ៗ ដូច្នេះ មនុស្ស ឬ សត្វទាំងពួង តែងមានភាសាប្រស្រ័យគ្នាជាធម្មតា ដូចជាមនុស្សចេះនិយាយគ្នា, ឆ្កែបក់កន្ទុយ, សារិកាស្រែក, . . .ៗ ខ្មែរយើងមានភាសាមួយប្រចាំជាតិ តាំងពីមុនគ្រិស្ដសករាជទៅទៀត គឺកើតមកពីពពួកអ្នកស្រុកដើម របស់យើងដែលរស់នៅតាម ភូមិ ស្រុកតូច.ធំ ដាច់ដោយពីគ្នា រហូតរួបរួមគ្នាបានជាអាណាចក្រមួយ នៅក្នុងការគ្រប់គ្រងព្រះនាងលីវយី ឬ ព្រះនាងនាគីសោមា ៗ

## ១– អំបូរនៃភាសា

ដោយសារនៅក្នុងសកលលោកនេះ មានភាសាផ្សេងៗគ្នាច្រើនពេក អ្នកប្រាជ្ញបានប្រមូលភាសាទាំងនោះមកចងក្រងជាក្រុមៗ ដែលមានលំនាំប្រហាក់ប្រហែលគ្នា គឺ ៖

១.អំបូរឥណ្ឌូ-អឺរ៉ុប (Indo-Européennes) បានដល់ភាសាគន្ថីរបស់ពួកឥណ្ឌា ដែលចេញមកពីសំស្ក្រឹត-បាលី និង របស់ពួកអឺរ៉ុប ដែលបែកចេញពីឡាតាំង-ក្រិក មកជាមូលដ្ឋាន ។

២–អំបូរសេមីទិក (Sémitiques)– បានដល់ភាសាអារ៉ាប់ ដែលបែកចេញមកពីគ្រាមភាសានានាក្នុងភូមិភាគអារ៉ាប់ភូមិភាគមជ្ឈិមបូព៌ាសព្វថ្ងៃនេះ ។

៣ –អំបូរ អូស្ត្រូ-អាស៊ី (Austro-Asiatique)

បានដល់ភាសាអ្នកនៅភូមិភាគអាស៊ីខាងត្បូង ឬនៅជិតខាងមហាសមុទ្រប៉ាស៊ីហ្វិក ។ អំបូរនេះ មានបែកជាសាខាតូចៗច្រើនទៀតគឺ ៖

- ម៉ាឡាយូ-ប៉ូលីណេស៊ី (ម៉ាឡេ-ហ្វីលីពីន ហាវៃ, ...)
- មន-ខ្មែរ (ខ្មែរ ភូមា លាវ- មន, ...)
- ថៃ (សៀម- យួន- ចិន, ...)

## គ- លក្ខណៈនៃភាសាខ្មែរ

ដែលនឹងរាប់ជាភាសាមួយបាន លុះត្រាតែមានលក្ខណៈច្បាស់លាស់ ជារបស់ខ្លួនដោយឡែកផ្ទាល់ខ្លួនយើង ។ ឯវិធីស្វែងរកពីលក្ខណៈដោយឡែករបស់យើងនោះ ត្រូវសិក្សាតាមបែបនេះ ៖

ក- សូរសាស្ត្រ (Phonétique) - គឺការ

មេញ្ញូញសូរសំនៀងតាមលំអានរបស់យើង ៖

១. KUSALA> កុសល ។ GANGA > គង្គា , គង្គ ។ MANGALA> មង្គល ។ បវត្ត> ប្រព្រឹត្ត ។

ឧទាហរណ៍នេះ ឲ្យឃើញថា សំស្ក្រឹតក្តី បាលីក្តី ដែលខ្មែរខ្ចីមកប្រើក្នុងភាសាខ្លួន ខ្មែរពុំបានអានឲ្យដូចដើមនោះមិនទេ គឺបំបែរទៅតាមទំនួលសំដីខ្មែរទៅវិញ ។

២-រូបសាស្ត្រ (Morphologie ) គឺរបៀបផ្លាស់ប្តូររូបពាក្យតាមលិង្គ- វចនៈ- បុរិស-កាល នៃពាក្យនោះ តាមបញ្ញត្តិនៃវេយ្យាករណ៍ ។ ត្រង់នេះ គឺឃើញថា របៀបផ្លាស់ប្តូររូបសព្ទពីសំស្ក្រឹត-បាលី មកជាខ្មែរមិនគោរពតាមរូបសព្ទដើមរបស់គេឡើយ ព្រោះពាក្យណាដែលរូបដើមគេជាមានន័យដូច្នេះ ដល់ខ្មែរយើងប្រើទៅជាជាន័យដូច្នោះទៅវិញ ៖

១. បក្សី (អ្នកទ្រទ្រង់ស្លាប) > សត្វស្លាបញី ។

កុមារ (ក្មេងទាំងឡាយ) > ក្មេងប្រុស ។

តាមលក្ខណៈដើមរបស់ខ្មែរ ពុំសំខាន់ត្រង់ប្តូររូបពាក្យទៅតាមលិង្គវចនៈ បុរិស កាល ដូចសំស្ក្រឹតបាលីឡើយ បើគេចង់ប្រាប់ភេទនៃពាក្យនោះ គេពុំប្តូររូបទេ គេយកពាក្យផ្សេងមួយទៀតមកបំពេញន័យ ៖

១. ជ្រូកឈ្មោល, គោញី, ... ។

គ-និយណ្តាសាស្ត្រ (Sémaiique ).- គឺជាបែបសិក្សាខាងរកអត្ថន័យរបស់ពាក្យ ១ ម៉ាត់ៗ ដូចជាប្រវត្តិពាក្យ( Linguistique ); វាក្យសព្ទ (Vocabulaire ) និរុត្តិសាស្ត្រ( Etymologie ) ជាដើម ។

១.វិទ្យាល័យ(វិទ្យ=វិជ្ជា+អាល័យ=កន្លែង) បានន័យថាជាសាលាជាន់មធ្យមវិជ្ជាមួយបែបទៅវិញ។

## ឃ—សេចក្ដីសន្និដ្ឋាន

តាមការសង្កេតនេះ នាំឲ្យសន្និដ្ឋានបានថា ភាសាខ្មែរយើងកើតឡើងមកពីអារ្យធម៌នានាចូលមកស្រុកយើង ឋិតនៅក្នុងអំបូរធំមួយហៅថាអារ្យធម៌ អូស្ត្រូ-អាស៊ី (Austro-Asiatique) ហើយបែកជាអំបូរតូចមួយទៀតហៅថា មន-ខ្មែរ ។ លុះចំណោរមកមានអារ្យធម៌ឥណ្ឌាបញ្ចូល ភាសាសំស្ក្រឹត បាលីមកទៀត យើងក៏ប្រឌិតយកតាមលំនាំភាសាគន្ដី(Langue classique) ទាំងពីរនេះបន្ថែមចូលក្នុងភាសាយើង , ប៉ុន្តែ ច្រើនតែយកតែខាងន័យ (Signification ) ក្នុងផ្នែកនិយណ្ឌសាស្ត្រ តែប៉ុណ្ណោះ ។

# អំពីអក្សរខ្មែរ

## ក-សេចក្តីផ្តើម

អ្នកប្រាជ្ញទាំងឡាយ បានស្រាវជ្រាវរកឃើញថា អក្សរដែលមនុស្សប្រើក្នុងសកលលោកនេះ មានដើមកំណើតចេញមកពីពួកមជ្ឈិមបូព៌ា គឺដំបូងកាលពី៥០០០ ឆ្នាំ មុនគ្រិស្តសករាជ(១) ជនជាតិហេប្រឺបានប្រឌិតជាតួ/រូប ហើយជាតិហ្វេនីស៊ីបានចម្លង ហើយកែប្រែសម្រួល ទើបផ្សាយទៅគ្រប់ទិសទី មានមកពីឥណ្ឌា តាមរយៈពួកអារិយៈ និងទៅអឺរ៉ុបតាមរយៈពួកក្រិក(២)។ គោលវិធី( Méthode )នៃអក្សរនេះ គេប្រើបែបសំយោគវិធី (Méthode Synthétique )គឺមានការផ្សំស្រៈ-ព្យញ្ជនៈ

---

១- Cabinet des Poinçons de l'Imp. Nat. de France, modèle XXXI, Hiéroglyphes

២- J. Filliozat, L'Inde classique T.I.

ឲ្យកើតជាពាក្យ ៗ

នៅពេលជំណាលគ្នានេះ ជនជាតិចិន ក៏ពង្កើតបានជាតួអក្សរសម្រាប់សំគាល់ពាក្យសំដីដែរ តែគេប្រើបែប"មនោគតិវិធី"( Méthode Analitique )គឺប្រឌិតតួអក្សរតាមរូបភាពរបស់ពាក្យមួយៗតែម្តង ។. សរសេរដូចរូបឆ្កែ ហៅថា ឆ្កែ, គូររូបសេះ ហៅថាសេះ ៗ

### ១- លក្ខណៈអក្សរខ្មែរ

ជនជាតិខ្មែរយើងប្រឌិតយកលំនាំអក្សរតាមឥណ្ឌាផ្នែកខាងត្បូង គឺក្នុងចំណោមបែបសំយោគវិធី ៗ ប៉ុន្តែអក្សរយើង ពុំមែននៅគង់រូបរាងបេះបិទអក្សរដើមរបស់ឥណ្ឌាទេ គឺខ្មែរយើងយកមកកាឡៃបន្តិចម្តងៗ ជាច្រើនលើករហូតមកដល់បែបសព្វថ្ងៃនេះដែលឆ្ងាយដាច់ស្រឡះពីឥណ្ឌា ៗ តាមប្រវត្តិ យើងឃើញថា អក្សរខ្មែរ មាន

ប្រាកដឡើង កាលពីគ្រិស្តសតវត្សទី ២ ដោយអាងលើហេតុដូចតទៅនេះ ៖

កាលមុនគ្រិស្តសតវត្ស រហូតមកដល់សតវត្សទី ១ យើងពុំទាន់មានតួអក្សរប្រើប្រាស់ទេ ទំនងជាកាលនោះ បើគេចង់កត់សំគាល់អ្វីមួយ គេប្រើតែវិធីចងចាំក្នុងចិត្តឬឆ្លាក់ឈើឆ្លាក់ថ្មជាគ្រឿងចំណាំៗ លុះមកដល់សតវត្សទី- ៣ ( គ.ស. ២២៣) ស្រាប់តែមានសិលា - ចារឹកមួយរបស់ព្រះបាទស្រីមារៈនៅស្រុកវ៉ូកាញ់(១) ខេត្តញ៉ាត្រាងសព្វថ្ងៃដែលកាលនោះជាដីខ្មែរ មានសរសេរជាអក្សរខ្មែរលើថ្មពីរផ្ទាំង គឺមួយជាភាសាសំស្ក្រឹត និងមួយទៀតជាភាសាខ្មែរបុរាណ ។ ហើយអក្សរ ដែលចារឹកនឹងថ្មនោះ មានរបៀបរៀបរយជាស្រេច ។

---

១-សូមអានសៀវភៅប្រវត្តិពុទ្ធសាសនានៅប្រទេសកម្ពុជា របស់ព្រះភិក្ខុប៉ាង-ខាត់ ផ្សាយពីពុទ្ធសាសនបណ្ឌិតទំព័រ ៤៣-៤៤-៤៥។

ក- សេចក្ដីសន្និដ្ឋាន

ដូច្នេះ ទើបអ្នកស្រាវជ្រាវសន្និដ្ឋានបានថា ៖ បើមានការរៀបចំល្អដូច្នេះ អក្សរនេះពុំមែនទើបនឹងកើតទេ គឺពិតជាកើតតាំងពីសតវត្សមុនម្ល៉េះ គឺកាលពីសតវត្សទី២ នោះឯង ។ ឯពត៌មានថា អក្សរយើងយកលំនាំតាមឥណ្ឌាខាងត្បូងនោះ ដោយហេតុអ្នកស្រាវជ្រាវបានយកសិលាចារឹកអក្សរខ្មែរកាលនោះ ទៅផ្ទឹមៗ ឃើញមានភាពប្រហាក់ប្រហែលគ្នាច្រើន ជាមួយអក្សរឥណ្ឌា គឺសម័យរាជ្យព្រះបាទបល្លវៈ ទិសឥណ្ឌាខាងត្បូង កាលមុនគ្រិស្តសតវត្សបន្តិច[១] ។

ខ្មែរយើងជាជាតិមួយមានទេពកោសល្យផ្ទាល់ខ្លួន

---

១-សូមអានសៀវភៅភាសាខ្មែររបស់លោកអៀវ-កើស ទំព័រ៥៥។

ឯង ហេតុនេះហើយបានជាទោះបីជាយើងប្រឌិតយកលំនាំអក្សរ ឬ អ្វីៗ ជាមែកធាងវប្បធម៌មកពីប្រទេសណាក៏ដោយ យើងតែងច្នៃរចនាបែបផែនវិជ្ជានោះឲ្យទាល់តែមានលក្ខណៈប្លែកពិសេសសមជារបស់ជាតិយើង ។

ឯរូបរាងអក្សរដែលយើងប្រើសព្វថ្ងៃជាកេរ្តិ៍នៃអក្សរដែលបង្កើតឡើងតាំងពីដើមបង្អស់នោះមក ដោយមានកែប្រែសម្រួល អស់វារៈ ១២ លើកមកហើយ ។

# អំពីសិល្បៈខ្មែរ

## ក- សេចក្តីផ្តើម

មុននឹងសិក្សាអំពីសិល្បៈខ្មែរឲ្យបានច្បាស់លាស់ គួរគប្បីយើងយល់ពីសិល្បៈក្នុងសកលលោកជាមុនសិន ។

តាមប្រវត្តិនៃសិល្បៈរបស់ជនជាតិទាំងឡាយនៅក្នុងពិភពលោកនេះ អ្នកប្រាជ្ញបានចែកជាប្រភេទសម្រាប់ឲ្យបានងាយស្រួលសិក្សាជាបីប្រភេទផ្សេងៗគ្នា តាមបែបបទទំនងនៃសិល្បៈនោះៗ គឺ ៖

១- សិល្បៈខាងសម្ភស្ស (Art charnel) - បានដល់សិល្បៈបញ្ចេញរូបភាព-សាច់ឈាម នៃ

មនុស្សជាលំអ   ជាគោលធំ, ដឹកនាំឲ្យមានសំរើបកើត

ឡើងបាន  ដូចយ៉ាងសិល្បៈផ្នែកអរូបសព្វថ្ងៃ ៖

១. ឆ្លាក់រូបស្រីកាយអាក្រាត, រចាំស្លៀកពាក់បិទបាំង

កេរខ្មាសបន្តិចបន្តួច, តែងកាយដោយសំលៀកបំពាក់ខ្លី

ដើម្បីបញ្ចេញសាច់, ...។ល។

២– សិល្បៈខាងគំនិត ( Art cérébral ).–

បានដល់បណ្ដាសិល្បៈ ដែលនិយមភ្ជាប់គំនិតទៅ

ក្នុងសិល្បៈ គឺយកឧត្ដមគតិធ្វើជាគោលធំ បានសេចក្ដី

ថា សិល្បៈខាងនេះឲ្យមានន័យច្រើនក្នុងនោះផង មាន

របាំធ្វើកាយវិការតាមន័យអ្វីមួយ ឬ រូបគំនូរ រូបចម្លាក់

មានបៃបបទលាតត្រដាងពីបញ្ហាណាមួយជាដើម ។

១. រាំលូកដៃទៅបេះផ្កាបានយកមកទុក ។

២- សិល្បៈសភាវគតិ (Art instinctif).- គឺជាសិល្បៈនិយមតាមការប្រព្រឹត្តទៅ នៃលំនាំឬកពា ចរិតមនុស្សគ្រប់ៗ តែម្តង គឺជា សិល្បៈតែគ្មានអ្វីជាសិល្បៈទេ គ្រាន់តែបញ្ចេញៗ ទៅប៉ុណ្ណោះ ។ បែបនេះក៏ដូចជាសិល្បៈពួកស្លែកខ្មៅសព្វថ្ងៃនេះ ។

យើងឃើញមកហើយ ក្នុងចំណោមសិល្បៈទាំងបីប្រភេទនេះ ខ្មែរយើងស្ថិតក្នុងពួកទី ២ គឺពួកនិយមការគិតធ្វើជាធំ បានន័យថា ដើម្បីឲ្យកើតជាសិល្បៈនីមួយ ៗ ខ្មែរយើងនិយមភ្ជាប់គំនិត និង ឲ្យន័យទៅក្នុងសិល្បៈទាំងនោះ បើគ្មានន័យទេ យើងពុំព្រមទទួលស្គាល់ថាជាសិល្បៈល្អឡើយ ។

ក្នុងសិល្បៈនៃជាតិនីមួយ ៗ គេសង្កេតឃើញមាន ផែកធានសំខាន់ ៧ យ៉ាងដែលហៅថាសិល្បៈច្បងគឺ ៖

១. ខាងសូរសម្លេង (ចម្រៀង-ភ្លេង —Chants-musique);

២. ខាងកាយវិការ (ល្ខោន-របាំ —Théâtre-Danse);

៣- ខាងពាក្យសំដី (កាព្យឃ្លោង — Poésie);

៤-ខាងពណ៌សម្បុរ (គំនូរផាត់ពណ៌ Peinture);

៥. ខាងភាពធំមាំ (ស្ថាបត្យកម្ម —Architecture)

៦- ខាងកងវេរ (រូបផ៉ាន់-រូបចម្លាក់ —Modelage-Sculture);

៧- ខាងរូបភាពឆាយាចិត្រ (រូបថត-ភាពយន្ត —Photographie-Cinématographie

អ្នកសិក្សាបានបញ្ចូលទៀតថា សិល្បៈទាំង ៧

សាខានេះកើតចេញមកអំពីមនោសញ្ចេតនារបស់មនុស្ស អាស្រ័យដោយវេទនារម្មណ៍ទាំង ៥ គឺ បញ្ចិន្ទ្រិយ(Les cinq sens )កាលណាមនុស្សមានរូបកាយហើយមនុស្ស តែងសោយអារម្មណ៍ ហើយខាក់បញ្ចេញនូវអារម្មណ៍ នោះវិញ បង្កើតទៅជាសិល្បៈផ្សេងៗ សិល្បៈសំខាន់ ៗបម្រកនេះហៅថា សិល្បៈធ្ងន់ (Arts majeurs) ។ សព្វថ្ងៃនេះ គេបង្កើតបានជាសិល្បៈបន្ទាប់បន្សំ ( Arts mineurs) ច្រើនទៀត ដូចជាការតែងកាយ-ការលំអផ្ទះ ការប៉ាក់ជុល ។ល។

ក្នុងបណ្តាសិល្បៈទាំង ៦ ខាងដើម ដែលរាប់ខាង លើ ខ្មែរយើងមានមកតាំងពីបុរមបុរាណមកហើយ ហើយ មានឥទ្ធិពលខ្លាំងក្លាផ្សាយពេញភូមិភាគសុវណ្ណភូមិយើង នេះផង ដូចជាមានជាតិជិតខាងខ្លះបានចម្លងយកលំនាំ

គាមយើង ទៅធ្វើជាសិល្បៈគេជាដើម ក្រៅពីនេះមាន

កស្តាំងនៅក្នុងមជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ នៅទ្វីប

អឺរុប ដែលគេស្គាល់សិល្បះយើងច្បាស់ជាងគេនៅចុង

បូពានេះ ។ មិនតែប៉ុណ្ណោះសោត យើងឃើញផងជាតិ

យើងភាគច្រើនណាស់ ដែលប្រកបអាជីវកម្មក្នុងរបរ

ដែលជាសិល្បៈ ដូចយើងរាប់សាខាមកខាងលើ មាន

ជាងឆ្លាក់ - ជាងទង - ជាងគំនូ - ជាងសំណង់ - គរឺ.ឆ្អក

គ្រឿងរាំ ។ល។ ព្រមទាំងមាននៅសល់កេរ្តិ៍ដំណែលពី

បុរាណកាលច្រើនបែប-យ៉ាង ទុករហូតដល់យើង

សព្វថ្ងៃនេះផង ។

ឯសិល្បៈទី ៧ យើងទើបតែបង្កើនបែបពីគេមក

គាក់តែងនៅពេលថ្មី ៗ នេះ ។

# លទ្ធិព្រាហ្មណ៍ ឬ ព្រហ្មណលទ្ធិ

អារ្យធម៌ទាំងឡាយ តែងកើតចេញមកពីលទ្ធិ និងសាសនា ។ ហេតុនេះបានជាពពួកបស្ចិមប្រទេស ខិតខំព្យាយាមចម្លងលទ្ធិសាសនា អំពីពួកអាស៊ីយកទៅ ធ្វើជាមូលដ្ឋាននៃអារ្យធម៌ខ្លួន ។ អារ្យធម៌ខ្មែរក៏បែក ចេញពីលទ្ធិសាសនាច្រើនដែរ ដូច្នេះ យើងលើកយក លទ្ធិព្រាហ្មណ៍ដែលចាស់បុរមបុរាណជាងគេ ហើយដែល បានចូលមកពាសពេញក្នុងអារ្យធម៌យើង មកសិក្សា ។

## ប្រវត្តិដើមនៃលទ្ធិព្រាហ្មណ៍

ដែលហៅថា „ លទ្ធិព្រាហ្មណ៍ ” ពុំមែន គំនិតកើតពីជនម្នាក់ៗឡើយ គឺប្រជុំនៃក្បួនខ្នាតគម្ពីរ ផ្សេងៗនិងកម្រងមតិជំនឿច្រើនបែបច្រើនយ៉ាង ដែល អ្នកស្រុកនិយមបង្កើតតៗគ្នាឡើង នៅក្នុងសម័យកណ្ដា

សុទ្ធតែជាគោលគំនិត ឬគោលជំនឿរបស់ខ្លួនទៅលើអគ្គទេវៈជាអាទិទេព ។ លទ្ធិនេះផុសផ្តើមឡើងដោយមនុស្សបុរាណឆ្ងាយ រកកំណត់ពេលពុំបាន ដោយការគោរពបូជាទេពតាមួយអង្គៗ ដោយឡែកៗពីគ្នា តាមនិគមក្រុមពួក ក្នុងបណ្តាអ្នកស្រុកនៅដាច់ស្រយាល ជាប់តាំងពីច្រើនពាន់ឆ្នាំមុនគ្រិស្តសករាជ ។ គេកត់សំគាល់បានថា មនុស្សមួយពួក មួយក្រុមកាលនោះ ចេះបង្កើតមន្តស្មូត្រប្រកាសបួងសួងអាទិទេព ហៅថា «សូក្តី» ។ រីឯអាទិទេពដែលគេរាប់អានទាំងនេះ មានច្រើនណាស់ គេនៅស្គាល់នាមដល់សព្វថ្ងៃនេះខ្លះ ហើយខ្លះទៀតក៏បាត់បង់នាមសូន្យទៅក៏មាន ។

## អាទិទេពក្នុងលទ្ធិព្រាហ្មណ៍

អាទិទេពដែលគេស្គាល់ឈ្មោះបាននោះ មាន

នាទីហូរហែគ្នាតាមជំនឿរបស់ពួកព្រាហ្មណ៍ ព្រោះតាមពិត អាទិទេពទាំងនោះគ្រាន់តែជាអរូបធម៌ (មានតែនាម) ពុំមែនជារូបធម៌ (មានរូបពិត) ទេ ។

ជំហានទៀតអ្នកស្រុកនាំគ្នាគោរពបូជាទេវៈផ្សេង ៗ មាន៖ នាមថារុទ្រ វរុណ អគ្គិវាយុ,... ដែលជាទេពតាតំណាងធម្មជាតិ គឺ៖ ដី-ទឹក-ភ្លើង-ខ្យល់ ...។ ការគោរពទេពតាទាំងនេះគ្រាន់តែមានជាពាក្យស្តុតិគឺបទស្តូត្របួងសួងនិងសរសើរគុណតែប៉ុណ្ណោះ ។ លុះមកដល់សម័យ<u>មានគម្ពីរវេទ ទើបគេប្រតិបត្តិតាមវេទនោះព្រមទាំងពិធីយជ្ញ ឬ យញ្ញបូជា ការលះបង់ (Sacrifice)</u> ក៏កើតឡើងដែរ ។ ពួកព្រាហ្មណ៍បង្កើតទេពតាធំមួយអង្គ ឲ្យនាមថា «ឥន្ទ្រ ឬទេវរាជ» ដែលមានទេពតាតូចទាំងពួងខាងលើជាបរិវារ ហើយគេនាំគ្នាជឿថា គឺជាឥន្ទ្រ នេះ

ហើយជាអ្នកកសាងលោក ហើយប្រទានក្បួនច្បាប់មកដល់ពួកម្ចាស់ ១ ឲ្យគេមកពួកព្រាហ្មណ៍ ទុកជាគោលគោរពប្រតិបត្តិ ។ ហេតុនេះក្នុងវេទរបស់ពួកព្រាហ្មណ៍មានបទសូត្របួងសួងសរសើរព្រះឥន្ទ្រ និងថ្វាយទឹកសោមដល់ព្រះឥន្ទ្រ ។

ជាដំណាក់ព្រាហ្មណ៍លែងគោរពឥន្ទ្រៈ ដោយនាំគ្នាយល់ថា ឥន្ទ្រៈមានប្រពន្ធច្រើន–ផឹកសេពទឹកសោម ពុំគិតច្បាំងបង្ក្រាបពួកអសុរ បណ្ដោយឲ្យអសុរយាយីសេចក្ដីសុខ របស់មនុស្ស ។ គេក៏នាំគ្នាបង្កើតទេពតាថ្មីមួយទៀតនាមថា «ព្រហ្ម» ហើយឲ្យព្រហ្មប្រកបដោយព្រហ្មចរិយធម៌ គឺមិនមានប្រពន្ធ មិនសេពសុរា ។ល។ លុះគេនាំគ្នាគោរពប្រតិបត្តិតាមព្រហ្មទៅ ក៏បានសុខសាន្ត ទើបនាំគ្នាជឿថា ព្រហ្ម សក្តិសិទ្ធិជាងឥន្ទ្រៈ ។

វេលាដែលជនជាតិឥណ្ឌា ត្រូវបែកបាក់គ្នាជាពីរពួក ដោយសារពួកអារ្យ៉ាន មកកាន់ទីលំនៅខាងដីខ្ពស់ ហើយពួកទ្រាវិដរត់ទៅនៅតាមដីទំនាបនោះ គេក៏បំបែកឲ្យមានអាទិទេពពីរអង្គទៀត គឺ៖

– ព្រះឥស្វរ ឬ ព្រ សិះវៈ ស្ថិតនៅលើភ្នំកៃឡាស ជិះគោសុនន្ទិ សម្រាប់ពួកអារ្យ៉ានគោរពបូជា ។

– ព្រះនារាយណ៍ ឬ ព្រះវិស្ណុស្ថិតនៅកណ្ដាលសមុទ្រ ជិះនាគវាសុក្រី សម្រាប់ពួកទ្រាវិដគោរព ។

អាទិទេពពីរអង្គក្រោយនេះ ជាអំណោយផ្ទាល់របស់ព្រះព្រហ្មបែងចែកឲ្យ គឺគេនិយាយថា៖ កាលនោះព្រះព្រហ្មចុះមកធ្វើតបៈ ដល់ភ្លៅបែកញើសខ្លាំង ក៏យកឈើទាក់ភ្លើងមកកៀរញើស ។ ឈើនោះកូកជាចំសាច់ ព្រះព្រហ្មមានស្រក់ឈាមពីដំណាក់ ក៏បង្កើតបានជា

អង្គព្រះសិវៈ និង ព្រះវិស្ណុ នេះឡើង ។

តាមសេចក្ដីសង្ខេបជាសរុប អ្នកប្រាជ្ញបានសន្និដ្ឋានថា ជំនឿនៅក្នុងលទ្ធិនេះទាំងមូល កើតឡើងពីការសន្មត់របស់ពួកព្រាហ្មណ៍គឺសន្មត់ឲ្យមានទេវ, មានអាទិទេព , ឲ្យមានទណ្ឌកម្ម , ឲ្យមានវាក្យនប្បាប់ទុកជាតំណាមក ហើយដែលកាន់តែកែប្រែបន្តិចម្ដង ៗ ឲ្យបានទៅជាអារ្យធម៌ឥណ្ឌា ។

## គោលវិជ្ជានៃលទ្ធិព្រាហ្មណ៍

កម្រងចំណោះនៃលទ្ធិព្រាហ្មណ៍ ដំបូងឡើងកើតពីបទ «ស្តុតិ» ដែលពួកអ្នកគោរពអាទិទេពតូច ៗ បានតាក់តែងឡើងជាពាក្យខ្លួន ៗ ។ តមក ពួកព្រាហ្មណ៍ នាំគ្នាប្រមូលកម្រងស្តុតិនោះ មកបង្គ្រងតាមពួក និងតែងបន្ថែមជាពាក្យឃ្លោងហៅថា « កាវ្យៈ » ឲ្យមានឡើង

ជាគម្ពីរហៅថា "វេទ" សំខាន់គឺត្រៃវេទ ដែលមាន ៖

១-ឫគ្វេទ ឬ ឫគ្សំហិតា. ជាបទសូត្រធ្វើយញ្ញ ។

២-យជុរវេទ ឬ យជុរសំហិតា -ជារូបមន្តសម្រាប់រៀបរណ្ដាប់ធ្វើយញ្ញ ។

៣-សាមវេទ ឬ សាមសំហិតា.- ជាបទឆន្ទសូត្រថ្វាយទឹកសោម ។

ក្រោយមកហៅថា " ចតុវេទ " គឺមានវេទទាំងបីនេះនិងថែមវេទមួយទៀតហៅថា "អថវវេទ ឬ អថវសំ-ហិតា" ដែលជាមន្តបណ្ដេញខ្មោចបិសាច ។ នៅសម័យចុងក្រោយនៃលទ្ធិនិយមវេទ ក៏កើតមានគម្ពីរកម្រងវិជ្ជាមួយឈ្មោះ " វេទាន្តៈ " ដែលអធិប្បាយពន្យល់ពីវេទដើមទាំងអស់នេះ បានគ្រប់សព្វ ។

# ព្រះពុទ្ធសាសនា

ក្នុងពេលដែលលទ្ធិព្រាហ្មណ៍កំពុងចេញជាជំនឿច្រើនបែប រហូតដល់មានអ្នកខ្លះធុញទ្រាន់នោះ ពុទ្ធសាសនា ក៏កើតឡើងដោយសារការត្រិះរិះរបស់មនុស្សច្រើននាក់ បានសេចក្ដីថាពុទ្ធសាសនាពុំមែនកើតឡើងកណ្ដាលមកពីអ្នកឆោតល្ងង់ទេ គឺគ្រានោះមានអ្នករិះគិតពិចារណាជាច្រើនគ្នាណាស់ ប៉ុន្តែព្រះពុទ្ធបានរកឃើញហៅថា ត្រាស់ដឹង,, ដូចជាឃើញ "អដ្ឋង្គិកមគ្គ" គឺផ្លូវល្អ៨យ៉ាងទៅកាន់ការរំលត់ទុក្ខ ត្រាស់ដឹង បានន័យថា "រកឃើញ "Découverte នូវសភាពបរិសុទ្ធ ក្នុងពុទ្ធិទាំងឡាយ (Connaissances )ៗ គំនិតរកឃើញកើតពីមនុស្ស ពុំមែនជាអាទិទេពបង្កើតទេ ៗ មុននឹងត្រាស់ដឹងព្រះពុទ្ធមានមាតាបិតា មានវង្សត្រកូលដូចមនុស្សធម្មតា

ហើយវិធីរក «ការត្រាស់ដឹងសព្វញ្ញុតញ្ញាណ»នេះ ក៏សម្រាប់ជាប្រយោជន៍មនុស្សផងគ្នា ។

## ប្រវត្តិពុទ្ធសាសនា

ព្រះពុទ្ធមុននឹងបានត្រាស់ ទ្រង់នាមថា «សិទ្ធត្ថ» ជារាជបុត្រ នៃព្រះបាទសុទ្ធោទន និង ព្រះនាងសិរិមហាមាយា ស្ថិតនៅក្នុងត្រកូលសក្យៈ នា ដែនកបិលព័ស្ដុ ក្នុងកំណត់ព្រះជន្មាយុ ២៩ ឆ្នាំ ព្រះអង្គបានចេញសាងផ្នួសស្វែងរកសម្មាសម្ពោធិញ្ញាណ អស់រយៈ ៦ ឆ្នាំ ទើបបានត្រាស់ដឹង ។ បន្ទាប់ពីត្រាស់ហើយ ព្រះអង្គបានទេសនាប្រៀនប្រដៅអ្នកស្រុកពីទីមួយទៅទីមួយ អស់រយៈ ៤៥ឆ្នាំ បូករួមជាកំណត់ ៨០ឆ្នាំគត់ ព្រះអង្គចូលព្រះបរិនិព្វាន ។

ក្រោយពុទ្ធនិព្វាន៤ខែ ដោយមានការកើតមន្ទិលក្នុង

ពុទ្ធនិព្វាន សាវ័កទាំងឡាយក៏បើកពេលប្រជុំពិភាក្សាធម៌
វិន័យហៅថា "បឋមសង្គាយនា" ដើម្បីរៀបចំតម្រឹម
តម្រង់ឲ្យមានផ្នែកជាក់លាក់គឺ ព្រះវិន័យ ព្រះសូត្រ និង
ព្រះអភិធម្ម ។ លុះបំណារមក១០០ឆ្នាំដោយខ្វាបគោល
ប្រតិបត្តិ ក្នុងពុទ្ធសាសនា កាន់តែរាតទៅព្រះសង្ឃ
ទាំងអស់ ជំនាន់នោះ ក៏បានប្រជុំគ្នាធ្វើសង្គាយនាទី
២ទៀត ។ បន្ទាប់មកក្រោយពុទ្ធនិព្វាន២៣៤ឆ្នាំ មាន
ការប្រជុំសង្គាយនាជាលើកទី៣ដើម្បីផ្ទៀនផ្ទាត់ធម៌វិន័យ
នោះ ព្រមទាំងចាត់មនេស្របាយផ្សាយ ព្រះពុទ្ធសាសនា
ទៅគ្រប់ទិសទីផង ។ លុះបាន២ឆ្នាំបន្ទាប់មក ពុទ្ធសាស-
នាក៏បានផ្សាយ ទៅដល់ស្រុកលង្កាក៏មានធ្វើសង្គាយនា
ជាលើកទី៤ ។ តមក ក្រោយពុទ្ធនិព្វាន៤៣៣ឆ្នាំទើប
មានសង្គាយនាជាលើកទី៥ ចាប់ធ្វើការកត់ត្រាជាលាយ

លក្ខណ៍អក្សរបានជាគម្ពីរឡើង ដោយប្រើអក្សរ-ភាសាសីហឡៈ ។ លុះដល់ពុទ្ធសាសនា ៩៥៦ ទើបព្រះពុទ្ធឃោសាប្រែគម្ពី ជាមគធភាសា ។

អាស្រ័យការកើតមានវិបត្តិខ្លះ ក្នុងពាក្យព្រះពុទ្ធយ៉ាងនេះហើយ បានជាអ្នកប្រតិបត្តិមានជំនឿបែកគ្នាទៅជានិកាយពីរគឺ ៖

១-ថេរវាទ ឬ ទក្ខិណនិកាយ ដែលសព្វ-ថ្ងៃហៅថា ហីនយាន គឺការគោរពចំពោះគោលដែលនិយមតាមការប្រជុំព្រះថេរៈទាំងឡាយចងចាំ ហើយចងក្រងទុកមក ។

២-អាចរិយវាទ ឬ ឧត្តរនិកាយ សព្វថ្ងៃហៅថា មហាយាន គឺការនិយមគោរពតាមពួកអាចារ្យបានកែសម្រួលបន្ថែមបន្ថយខ្លះ ។

## ទស្សនៈនៃពុទ្ធសាសនា

ដើម្បីនឹងត្រាស់ដឹងជាព្រះពុទ្ធនីមួយ ៗ ពោធិសត្វត្រូវមានពោធិសម្ភារ ដែលកើតឡើងពីការសាងបារមីទាំង ១០ ហៅ "ទសបារមី" ។ ការរកឃើញជាដើមបំផុតគឺបញ្ហា „ សុខ " និង " ទុក្ខ " របស់មនុស្សដែលមានឡើងដោយសារតែ ៤ ជាតិ – ជរា – ព្យាធិ – មរណៈ" ។ ដើម្បីចៀសពី "ទុក្ខ" នេះ មានតែអដ្ឋង្គិកមគ្គ ដែលមាន"សម្មាទិដ្ឋិ គឺ ការយល់ឃើញត្រូវ ជា÷ „ផល„ ដែលមនុស្សបានទទួលគឺ កើតមកពី „កម្ម"របស់ខ្លួនបានធ្វើ ។ បានសេចក្តីថា កម្មៈជាអំពើ (Action) ដែលមនុស្សប្រព្រឹត្តគ្រប់ពេលវេលាហើយ នាំឲ្យកើតជាបច្ច័យ ជាផល (Résultat) ផ្តល់មកឲ្យអ្នកប្រព្រឹត្តនេះវិញ ពុំដែលខាននោះជាដើម ។ និងនៅទីបំផុត

មាន"សម្មាសមាធិ" គឺការតាំងចិត្តឲ្យនឹងនួន ឬ សង្រួម
ចិត្តដោយហ្មត់ចត់ ។

អដ្ឋង្គិកមគ្គនេះ បានន័យថា ផ្លូវដ៏ប្រសើរដែលមាន
៨យ៉ាងសម្រាប់ឆ្ពោះទៅរកការសុខស្ងប់ ផុតរលត់នូវទុក្ខ
គឺសុខបរិសុទ្ធដែលយើងសព្វថ្ងៃ មិនអាចយល់បានយល់
បាន ហៅថា"និព្វាន" ។

គោលសិក្សានៃពុទ្ធសាសនា

គោលវិជ្ជានៃពុទ្ធសាសនា អាស្រ័យលើការសិក្សា
ពីរបែបគឺ ៖

១-គន្ថធុរៈ - គឺជាការស្វែងសិក្សា បែបទ្រឹស្តី
រៀនអក្សរខគម្ពីរដីកា ។ របៀបសិក្សាបែបនេះសម្រាប់
អ្នកមានវ័យនៅក្មេង ទើបអនុវត្តបាន ព្រោះក្បួនខ្នាត
មានអត្ថជាលជ្រៅហៅថា "ព្រះត្រៃបិដក" មាន៖

–សុត្តន្តបិដក ឬ ព្រះសូត្រ ជារឿងរ៉ាវនិទានឬជាកេផ្សេងៗ ដែលសម្រាប់ណែនាំ ពុទ្ធបរិស័ទឲ្យជ្រះថ្លាមានសទ្ធា និងដឹងគុណទោសតាមគន្លងធម៌ព្រះពុទ្ធ ។

–វិន័យបិដក ឬ ព្រះវិន័យ ( Disciplines) ដែលជាច្បាប់បញ្ញត្តិ ឬជាលក្ខខណ្ឌសម្រាប់កំណត់តម្រឹមតម្រង់ពុទ្ធបរិស័ទ ឲ្យមានក្រិត្យក្រមល្អ ។

–អភិធម្មបិដក ឬ ព្រះអភិធម្ម(Métaphysique)ជាបទពិចារណាយ៉ាងល្អិតល្អន់ ឬវិធីត្រិះរិះរកការដោះស្រាយបញ្ហា ឬពិនិត្យពីរូបធាតុដ៏សុខុមណាមួយ មានបញ្ហាកើតស្លាប់ជាដើម ។

២–វិបស្សនាធុរៈ គឺជាការស្វែងសិក្សាបែបប្រតិបត្តិចិត្ត គឺការហាត់ទម្លាប់ចិត្ត ហៅថាធ្វើ"កម្មដ្ឋាន" មាន ៖

• សមថកម្មដ្ឋាន សម្រាប់រំងាប់ចិត្តឲ្យស្ងប់

• វិបស្សនាកម្មដ្ឋាន សម្រាប់ធ្វើចិត្តឲ្យចេះត្រិះរិះ ។

ដូច្នេះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ សឹងស្រប ទៅតាមគោលវិធីវិទ្យាសាស្ត្រ (Procédé scientifique) គឺយកសតិបញ្ញា ធ្វើជាប្រដាប់ដុះមើលនូវធាតុផ្សេង ៗ មានរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ ជាដើម ។ ដូច្នេះនឹងសំគាល់ទ្រឹស្តីរបស់ព្រះពុទ្ធថាជា "លទ្ធិ" នោះ ពុំសូវសមសោះ គួរគប្បីតែទុកដាក់ថាជា ទស្សនវិជ្ជា (Philosophie) ឬ "ពុទ្ធសាសនា" ដែលបានន័យថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ (Doctrine Buddhique) ព្រោះហៅថាលទ្ធិនោះ គឺមានន័យថា ជំនឿទូលំទូលាយណាស់ ដូចជាលទ្ធិព្រាហ្មណ៍ឯនោះ ។

# អំពីអក្សរសិល្ប៍ខ្មែរ

## សេចក្តីផ្តើម.-

ដែលហៅថា «អក្សរសិល្ប៍» ពុំមែនសំដៅតែទៅលើតួអក្សរ ឬអ្វីដែលទាក់ទងតែជាមួយតួអក្សរប៉ុណ្ណោះទេ បើពោលឲ្យចំ គឺជាមែកធាងមួយយ៉ាងសំខាន់នៃអក្សរធម៌ខាងការតែងអធិប្បាយផ្សាយគំនិតផ្សេងៗ ឬ ចងក្រង នូវគតិសារៈសំខាន់គ្រប់ការលូតលាស់ ឬ សកម្មភាពនៃសាខាអក្សរធម៌ទាំងអស់ ។ ហេតុនេះហើយបានជានៅក្នុងស្នាដៃ ដែលហៅថាអក្សរសិល្ប៍នីមួយៗគេតែងឃើញមានការ និទានទាក់ទងទៅគ្រប់ផ្នែកអក្សរធម៌ ប៉ុន្តែ តាមវិធីសាស្ត្រដោយឡែកបន្តិចក្នុងនោះផង ដូចជា អត្ថបទព្រះលោមលោក-រឿងនិទាន ។ល។ ដូច្នេះដែលហៅអក្សរសិល្ប៍ គឺសម្គាល់ទៅលើអត្ថបទអក្សរ-សាស្ត្រ ពុំមែនតួអក្សរសាស្ត្រ (Lettres) ទេ ។

ជនជាតិខ្មែរយើង បានបង្កើតអក្សរសិល្ប៍តាំងពីយូរណាស់មកហើយ; គឺស្មើគ្នានឹងប្រវត្តិសាស្ត្រស្រុកយើង, សម្រាប់ដាមធ្យោបាយ ភ្ជាប់អារម្មណ៍ ទៅនឹងសន្តានចិត្តអ្នកស្រុកទូទៅៗ ឯនិក្ខេបបទ( Thèses )ច្រើនលើកយកគោលគំនិតខាងលទ្ធិនិងសាសនា ព្រមទាំងបញ្ហាមនុស្សជាតិខ្លះមកពន្យល់ ៗ រីឯវិទ្យានិពន្ធ (Thèmes)គឺបញ្ហា និងការដោះស្រាយក្នុងនោះវិញសម្បូណ៌ខាងបញ្ហាសង្គមកិច្ចបញ្ហាជំនឿលទ្ធិ សាសនាបញ្ហាជាតិ និង បញ្ហា ធុក្ខ និង សុខ ក្នុងលោកិយ ៗ

## ប្រភេទអក្សរសិល្ប៍

គេអាចចែកអក្សរសិល្ប៍ ជាផ្នែកធំៗពីរ គឺ ៖

### ១- អក្សរសិល្ប៍ពាក្យកាព្យ-

អក្សរសិល្ប៍ខ្មែរបុរាណ សម្បូណ៌សរសេរជា

ពាក្យកាព្យណាស់ ហើយកាព្យទាំងនោះ មានច្រើនប្រភេទទៅទៀតជាអាទិ៍ គឺ ៖

ក- ប្រភេទប្រលោមលោក(Genre romantique) គឺបែបសរសេរតំណើររឿងវែងឆ្ងាយ ប៉ុន្តែអធិប្បាយពីដើមដល់ចប់ជាពាក្យកាព្យ ៖ ១. រឿងកាកី; ក្រុងសុភមិត្រ; ព្រះជិនវង្ស ... ។

ខ- ប្រភេទឧបទេស(Genre didactique)គឺបែបកាព្យប្រៀនប្រដៅផ្សេងៗ និយមតាមជំនាន់និមួយៗ ៖

១.រឿងជាតកខ្លីៗ ១.ច្បាប់ក្រម,ពាក្យចាស់,ច្បាប់កេរ្តិ៍កាល ... ។

គ- ប្រភេទពីណគីតិ ( Genre lyrique ) គឺបែបពាក្យកាព្យខ្លីៗ សម្តែងពីមនោសញ្ចេតនា ចុះពីចិត្តផ្ទាល់ខ្លួន ដែលកវីយល់ឃើញពីបញ្ហាបច្ចុប្បន្នតែមួយ

ប្រកបដោយន័យពិរោះពិសា ៖

១. កាព្យព្រះរាជសម្ភារ - កាព្យសុន្ទរម៉ុក-កាព្យ

គុកកាមកិលេស . . . ។

ឃ - ប្រភេទបែបរិះគន់ (Genre satirique) គឺ

ជាសេចកាព្យខ្លះ ៗ និទានពីហេតុការណ៍អ្វីមួយដែលមិន

សមរម្យ ដោយមានលាយគំនិតរិះគន់ដាស់តឿនខ្លះ ៗ

គន់នោះផង ៖ ១. រឿងកនិពាសនគរវត្ត-រឿងរឡាមរាំង

រឿងកម្ពុជា, . . . ។

## ២- អក្សរសិល្ប៍ពាក្យរាយ -

គន់អក្សរសិល្ប៍ពាក្យរាយ ក៏មានបែកចេញជាច្រើន

ប្រភេទដែរ ដូចមានជាអាទិ៍គឺ ៖

ក - ប្រភេទរឿងល្បើក (Fables).- រឿងខ្លះ ៗ

ដែលកំប្លែងដោយបញ្ចេញគោលគំនិត ឬសីលធម៌គន់ន័យ

ដាស់តឿន ៖ ១- រឿងទន្សាយនិងខ្លា, ខ្លាឃ្មុំនិង ដើមពាន្ធ, វៃនិងស្រមោច ។ល។

ខ- ប្រភេទរឿងព្រេង (Contes légendaires).- ថែបរឿងប្រឌិតដូនវៃងដូនខ្មី មានមកជាយូរមកហើយ ពុំដឹងឈ្មោះអ្នកតែងមួយណាទេ ដូចជា រឿងនាងសក់ក្រអូប - រឿងព្រះថោងនាងនាគ . រឿងតាគោហេ . រឿងតាព្រហ្មយាយពៅ , រឿងអ្នកតាឃ្លាំងមឿង,...។

គ- ប្រភេទនវកថា (Nouvelles ) គឺជាថែប រឿងប្រឌិតក្រងឡើងខ្លី ៗ ប្រកបដោយបញ្ហាតូចល្មម ដែលឆាប់ដោះស្រាយរួចភ្លាមៗ ៖ ១- រឿងខ្លីៗ ក្នុងទស្សនាវដ្ដីពន្លឺថ្ងៃសៅរ៍- រឿងទាក់ដំរីក្នុងទស្សនាវដ្ដី កម្ពុជសុរិយា, រឿងដូងពាកស្លាប់, នារីនិងបុប្ផា ,...

ឃ -ប្រភេទប្រលោមលោក (Romans).- ជា

ថែបរឿងវែងដែលមានហេតុបញ្ហាច្បាស់លាស់ ហើយដោះស្រាយប្រកបដោយនិក្ខេបទត្រឹមត្រូវ ៖ ១. រឿងកុលាបប៉ៃលិន-រឿងផ្កាស្រពោន រឿងផ្កាវីកផ្កាពោយ ,...

៥- ប្រភេទរឿងល្ខោន (pièces de théâtres) ថែបសម្ដែងជាឆាកជាល្បុក ថែបសិល្បៈកាយវិការប្រកបដោយវិធីសាស្ត្រ ៖ ១. រឿងមៀមច្បងយើង, ថ្នាំ, សំបុកឥតមេបា ....

# ប្រវត្តិសង្ខេបនៃអក្សរសាស្ត្រខ្មែរ

អក្សរសាស្ត្រខ្មែរ កើតឡើងស្មើនឹងប្រវត្តិសាស្ត្រដែរ ដែលគួរកត់ត្រាបាន តាំងពីសតវត្សទី ១ នៃគ្រិស្ត-សករាជមក។ ឃើញថាមានរយៈវេលាយ៉ាងវែងពន់ពេក បើនឹងសិក្សាពីដំណើរវិវត្តន៍គ្រប់ ៗ ឆ្នាំមិនបាន។ ដូច្នេះ បានជាអ្នកសិក្សា និយមចែកសម័យកាលនេះជាបួនសម័យធំៗ និងពិនិត្យពីការចម្រើនលូតលាស់ ឬការអន់ថយតាមពេលវេលាទាំងនោះ ដូចតទៅ ÷

## ១. អក្សរសាស្ត្រសម័យមុនអង្គរ

( Préangkorien )

សម័យដំបូងនេះ មានរយៈវេលាវែងឆ្ងាយណាស់ គឺចាប់តាំងពីកទឹកដី កសាងភាព្យជមិមកទល់ផុតសតវត្ស

ទី ៨ ។ កាលនោះ រាជធានីយើងក៏នៅពុំទាន់នឹងន ជាប់លាប់ ការកសាងវប្បធម៌ជាតិមានអក្សរសាស្ត្រជាដើម ក៏នៅពុំទាន់មានជំហររឹងប៉ឹងដែរ ។ គេប្រទះឃើញបានខាងអក្សរសាស្ត្រខ្លះៗ តែនៅលើផ្ទាំងសិលា. បារិក និង រឿងរ៉ាវខាងសាសនាប៉ុណ្ណោះ ប៉ុន្តែឃើញថាមានការរៀនសូត្រច្រើន ព្រោះអ្នកប្រាជ្ញអក្សរសាស្ត្រជំនាន់នោះច្រើនជាពួកព្រាហ្មណ៍ ដែលបានទទួលការឧបត្ថម្ភពីព្រះមហាក្សត្រពេញបន្ទុក ។

## ២—អក្សរសាស្ត្រសម័យអង្គរ

( Epoque Angkorien)

រយៈកាលទី២នេះ រាប់ចាប់ពីសតវត្សទី៩ មកដល់ផុតសតវត្សទី១៤ ។ កាលនោះខ្មែរយើងកសាងបានជារាជធានីរុងរឿងអង្គរ ។ អារ្យធម៌ខ្មែរក៏ចាប់ពង្រីកពេញ

កម្លាំងតាមរយៈពួកព្រាហ្មណ៍ជាអ្នកប្រាជ្ញ និងព្រះរាជាព្រះអង្គឯងផង ដោយមានបង្កើតជាទីប្រជុំរាជបណ្ឌិតសម្រាប់កែទម្រង់និងផ្សព្វផ្សាយអក្សរសាស្ត្រជាតិឲ្យបានជ្រួតជ្រាបទៅពេញប្រទេស ។ ហេតុនេះ បានជាគេឃើញមានកេរ្តិ៍ដំណែលនៅសល់ជាច្រើន ដូចជាអត្ថបទសំខាន់ៗលើផ្ទាំងថ្ម ។ ក្រៅពីនេះ តាមអ្នកស្រាវជ្រាវជា មានអត្ថបទសរសេរលើក្រាំងស្បែកសត្វ ដូចជារឿងរាមកេរ្តិ៍ រឿងមហាភារត រឿងព្រេងនិទានជាប់នឹងមាត់អ្នកស្រុកជាដើម ។ គំនិតអក្សរសាស្ត្រសម័យនេះប្រកបដោយសេចក្តីសន្សឹម ឡើងដល់ថ្នាក់រុងរឿងបំផុតក្នុងប្រវត្តិអក្សរសាស្ត្រយើង ។

## ៣ - អក្សរសាស្ត្រសម័យក្រោយអង្គរ

( Post-angkorien )

កាលពីសម័យមុន អក្សរសាស្ត្រយើងកំពុងតែចំរើន ស្រាប់តែមកដល់ពេលនេះ ក៏ប្រែត្រឡប់ជាស្ងាត់សូន្យឈឹងសឹងតែបាត់អស់ដំណើរ នៃការវិវត្តអក្សរសាស្ត្រ អាស្រ័យដោយប្រវត្តិសាស្ត្រយើង ត្រូវចុះឱនថយ ព្រោះមានបច្ចាមិត្រមករាតត្បាត វាយយកបានក្រុងអង្គរ ហើយក្បួនខ្នាត ច្បាប់តម្រាក្នុងវប្បធម៌យើងទាំងប៉ុន្មាន ក៏ត្រូវខ្មាំងសត្រូវដណ្តើមយកទៅស្ទើរតែអស់ ៗ យើងនៅសេសសល់តិចតួច ក៏ជីកជញ្ជូននាំមករកទីក្រុងថ្មីតែដោយក្រុងថ្មីមិនទាន់ទៀងទាត់នៅឡើយ ថែមទាំងមានចលាចលដោយសារពួកសត្រូវចេះតែកំញើញពីក្រៅផង កើតទំនាស់ទាស់ទែងគ្នាក្នុងស្រុកផងទៀតនោះ ការចំរើនលូតលាស់ក៏បាត់សាបសូន្យ ៗ អភ័ព្វមួយកើតឡើងទៀត គឺពួកសត្រូវមកវាយបានបន្ទាយលង្វែក ដឹក

ផ្ញានបង្ហើយកស់ក្បួនខ្នាតខ្មែរយើង ពីគ្រឹមនោះទៅ ។ ចាប់តាំងពីនោះមក បើនរណាចង់ចេះដឹងតោងតែទៅតាមរៀនយកពីស្រុកគេយកមកវិញ ។ ក្នុងគ្រានោះ ក្បួនច្បាប់ទាំងឡាយខ្មែរយើងចារលើស្លឹករឹត និងសរសេរលើក្រាំងក្រដាសក្រាស់ៗ ។ ១៤?

លុះមកដល់ចុងសតវត្សទី ៨ មានអ្នកចេះដឹងក្រាស់ក្រែលបត្តិឡើងវិញ នៅក្នុងព្រះរាជ្យបត្តមនៃព្រះករុណាព្រះបាទអង្គឌួង ។ ព្រះអង្គទ្រង់ចាប់ស្ថាបនាអក្សរសាស្ត្រជាតិឡើងវិញ ដោយប្រមូលផ្តុំអ្នកចេះដឹងធ្វើជាក្រុមរាជបណ្ឌិត្យ កាក់តែងក្បួនខ្នាតឡើងវិញសាជាថ្មី ហើយចាប់ផ្សាយបង្ហាត់បង្រៀនអ្នកស្រុកទូទៅ ឲ្យបានចេះដឹងផង ។

## ៤- អក្សរសាស្ត្រសម័យបច្ចុប្បន្ន

( Epoque Contemporain )

សម័យទី៤ចាប់ផ្ដើមឡើងពី គ.ស ១៨៦៣ ដែលជាគ្រាដែលស្រុកខ្មែរយើង ធ្លាក់ខ្លួនទៅនៅក្រោមឲ្យពួកបស្ចិមប្រទេស ។ កំឡុងនេះ វប្បធម៌បស្ចិមប្រទេសក៏ហូរចូលស្រុកខ្មែរយើងបន្តិចម្ដងៗ តាមរយៈពួកជាតិបារាំងជាអ្នកអាណាព្យាបាលខ្មែរ ។ ក៏អ្នកនិពន្ធដែលកំពុងផ្ដុះបន្តៗគ្នាកាលពីរាជ្យព្រះបាទអង្គឌួងក៏នេះតែនៅបន្តសកម្មភាពទៅទៀត ប៉ុន្តែឧត្តមគតិក្នុងស្នាដៃរបស់ខ្លួន ក៏កាន់តែដេកដួលទៅក្នុងភាពអស់សង្ឃឹមលន្លង់ស្រគោចខ្លាំងឡើងដែរ ។ ឯការផ្សាយឃើញជាកើនចំរើនជាងមុន ព្រោះមានពុម្ពអក្សរបោះផ្សាយបានងាយជាងកាលចារលើស្លឹករឹតនិងសរសេរលើក្រាំង ។ លុះមកដល់ គ.ស.១៩៥៣ ពេលឯករាជ្យ អក្សរ-

សាស្ត្រខ្មែរក៏ប្រែភេទទៅតាមបែបអក្សរសាស្ត្រ សម័យនិយម ហើយបានដើរមុខមាត់ឡើងកាន់ហាន ជាអក្សរសាស្ត្រទំនើបថ្មីមានបែបបទបច្ចេកទេស ដោយត្រូវគេលើកយកមកសិក្សាយ៉ាងពេញលេញ ដូចយើងឃើញសព្វថ្ងៃនេះ ។

បណ្ណាគារ

សេង.ងួន.ហួ

លេខ ៦៧ វិថីព្រះបាទចន្ទរាជា

ភ្នំពេញ

តម្កល់ទុកតាមលេខ ០៧៣

ចុះថ្ងៃទី ៨ - ៤ - ៦៥

ប.ព.ទី ១ ចំនួន ១.០០០ ក្បាល